**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**
**លេខ** ៣៧៣ សជណ

*រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១៦*

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**ជម្រាបជូន**
**ឯកឧត្តម រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍**

**កម្មវត្ថុ** ៖ ករណីសំណើសុំការសម្រេចដ៏ខ្ពង់ខ្ពស់ពី**សម្តេចតេជោ នាយករដ្ឋមន្ត្រី** លើការដាក់ឲ្យប្រើប្រាស់គោលនយោបាយអភិវឌ្ឍន៍វិស័យទូរគមនាគមន៍-បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ។

**យោង** ៖ -លិខិតលេខ០២៩៧ បទ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ ២០១៦របស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
-ចំណាររបស់សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ ២០១៦ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ទីស្តីការគណៈរដ្ឋមន្ត្រី សូមជម្រាបជូនឯកឧត្តមមេត្តាជ្រាបថា ៖ ចំពោះករណីនេះ រាជរដ្ឋាភិបាលបានសម្រេចយល់ព្រមតាមសំណើរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ដាក់ឲ្យប្រើប្រាស់គោលនយោបាយអភិវឌ្ឍន៍វិស័យទូរគមនាគមន៍-បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ដោយមិនចាំបាច់ឆ្លងកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ដើម្បីពន្លឿនការអនុវត្តវិធានការនានាស្របតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣, បន្សីការអនុវត្តគោលនយោបាយនេះជាមួយនឹងច្បាប់ ស្តីពីទូរគមនាគមន៍ និងចង្អុលបន្ថែមទៀតលើវិធានការយុទ្ធសាស្ត្រនានា ក្នុងការអភិវឌ្ឍន៍វិស័យទូរគមនាគមន៍បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ដើម្បីរួមចំណែកដល់ការអភិវឌ្ឍន៍សង្គម និងកំណើនសេដ្ឋកិច្ចរបស់កម្ពុជា ក្នុងរយៈពេលប្រាំឆ្នាំខាងមុខ ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមមេត្តាជ្រាប និងចាត់ចែងអនុវត្តតាមការគួរ ។

**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**រដ្ឋលេខាធិការ**

**ឃឹម រស្មីដា**

ចម្លងជូន:
-ក្រសួងមហាផ្ទៃ
-ក្រសួងការពារជាតិ
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងព័ត៌មាន
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តម ឧបនាយករដ្ឋមន្ត្រី សុខ អាន
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# គោលនយោបាយ
# អភិវឌ្ឍន៍វិស័យទូរគមនាគមន៍-
# បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
# ឆ្នាំ២០២០

«ឆ្ពោះទៅសន្ធិភាព និងកម្មញ្ញភាពនៃបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន»

"Toward ICT connectedness and readiness"

រាជធានីភ្នំពេញ, ខែមេសា ឆ្នាំ២០១៦

# មាតិកា


*ទំព័រ*

**១.)- សេចក្តីផ្តើម** ...... **១**

១.១)-ភាពចាំបាច់នៃគោលនយោបាយអភិវឌ្ឍន៍វិស័យទូរគមនាគមន៍-បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន (**ទ-ប.គ.ព.**) ...... ១

១.២)-ការផ្សាភ្ជាប់វិស័យទូរគមនាគមន៍និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន (**ប.គ.ព.**) ...... ៣

**២.)- ស្ថានភាពនៃការអភិវឌ្ឍវិស័យទូរគមនាគមន៍-បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន (ទ-ប.គ.ព.) នៅកម្ពុជា** ...... **៥**

២.១)-កត្តាមូលដ្ឋានគ្រឹះទ្រទ្រង់ការអភិវឌ្ឍវិស័យទូរគមនាគមន៍-បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន (**ទ-ប.គ.ព.**). ...... ៥

២.២)-កម្មញភាពបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន (**ប.គ.ព.**) ...... ៩

២.៣)-កត្តានៃការប្រើប្រាស់សូហ្វវែរកម្មវិធី ...... ១៣

**៣.)- ចក្ខុវិស័យ** ...... **១៥**

**៤.)- គោលបំណងនិងគោលដៅ** ...... **១៥**

**៥.)- ក្របខ័ណ្ឌយុទ្ធសាស្ត្រ** ...... **១៧**

**៦.)- វិធានការគោលនយោបាយនិងផែនការសកម្មភាព** ...... **១៧**

៦.១)-ការពង្រឹងមូលដ្ឋាននៃការអភិវឌ្ឍវិស័យទូរគមនាគមន៍-បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន (**ទ-ប.គ.ព.**) ...... ១៧

៦.២)-ការពង្រឹងសន្តិសុខនិងការអភិវឌ្ឍឧស្សាហកម្មទូរគមនាគមន៍-បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន (**ទ-ប.គ.ព.**) ...... ២០

៦.៣)-ការជំរុញការប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន (**ប.គ.ព.**) ...... ២១

**៧.)- យន្តការដឹកនាំ សម្របសម្រួល និងអនុវត្តគោលនយោបាយ** ...... **២៣**

៧.១)-ស្ថាប័នដឹកនាំ សម្របសម្រួល និងការពង្រឹងអង្គភាពជំនាញ ...... ២៣

៧.២)-យន្តការពិគ្រោះយោបល់ជាមួយវិស័យឯកជន-ស្ថាប័នស្រាវជ្រាវ ...... ២៣

៧.៣)-កិច្ចសហប្រតិបត្តិការអន្តរជាតិ ...... ២៣

៧.៤)-ការគាំទ្រផ្នែកហិរញ្ញវត្ថុ ...... ២៣

៧.៥)-ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ...... ២៤

**៨.)- ការគ្រប់គ្រងហានិភ័យ** ...... **២៤**

៨.១)-ហានិភ័យពាក់ព័ន្ធនឹងការសម្របសម្រួលស្ថាប័ន ...... ២៤

៨.២)-ហានិភ័យពាក់ព័ន្ធនឹងការវិវត្តយ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យា ...... ២៤

**៩.)- សេចក្តីសន្និដ្ឋាន ........................................................................ ២៥**

**ឧបសម្ព័ន្ធ**

ឧបសម្ព័ន្ធទី១ វាក្យស័ព្ទ

ឧបសម្ព័ន្ធទី២ តារាងគម្រោងអាទិភាព

ឧបសម្ព័ន្ធទី៣ តារាងស្ថិតិនានា

## ១.)- សេចក្តីផ្តើម

### ១.១)-ភាពចាំបាច់នៃគោលនយោបាយអភិវឌ្ឍន៍វិស័យទូរគមនាគមន៍-បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន (ទ-ប.គ.ព.)

ទស្សនវិស័យវែងឆ្ងាយរបស់កម្ពុជាឆ្ពោះទៅឆ្នាំ២០៣០, ***«គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម»*** និង ***«យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣»*** បានចង្អុលបង្ហាញពីការប្រែប្រួលរចនាសម្ព័ន្ធសេដ្ឋកិច្ចកម្ពុជា ដែលកំពុងឈានទៅសម្រេចឋានៈប្រទេសកម្រិតចំណូលមធ្យម និងបានចាត់ទុកវិស័យទូរគមនាគមន៍និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានជាសសរស្តម្ភមួយក្នុងចំណោមសសរស្តម្ភដ៏មានសារៈសំខាន់ទាំងឡាយ ដើម្បីធ្វើជាមូលដ្ឋានគ្រឹះនៃកំណើនសេដ្ឋកិច្ចកម្ពុជា។ ក្នុងគោលដៅនេះ រាជរដ្ឋាភិបាលបានរៀបចំនិងដាក់ចេញនូវ ***«គោលនយោបាយអភិវឌ្ឍន៍វិស័យទូរគមនាគមន៍-បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន (ទ-ប.គ.ព.)»*** ដើម្បីជាមគ្គុទេសក៍ជំរុញការអភិវឌ្ឍវិស័យ **ទ-ប.គ.ព.** នៅកម្ពុជា ដែលនឹងរួមចំណែកដល់ការរក្សាកំណើនសេដ្ឋកិច្ចខ្ពស់ ប្រកបដោយចីរភាព និងបរិយាប័ន្ន។

ការប្រែប្រួលយ៉ាងឆាប់រហ័សនៃនិម្មាបនកម្មពិភពលោកនិងតំបន់ រួមទាំងទំនាក់ទំនងភូមិសាស្ត្រនយោបាយ បានគូសបញ្ជាក់ច្បាស់អំពីកាលានុវត្តភាព សម្រាប់ការអភិវឌ្ឍវិស័យ **ទ-ប.គ.ព.** ដែលធ្វើជាមូលដ្ឋានសំខាន់សម្រាប់ការអភិវឌ្ឍសង្គមនិងសេដ្ឋកិច្ចនៅកម្ពុជា។ នៅក្នុងក្របខ័ណ្ឌនៃកិច្ចសហប្រតិបត្តិការកម្រិតពិភពលោក នាសន្និសីទពេញអង្គ (Plenipotentiary Conference) ដែលមានការចូលរួមពីបណ្តាប្រទេសជាសមាជិករបស់សហភាពទូរគមនាគមន៍អន្តរជាតិ (International Telecommunication Union, ITU) និងបានប្រព្រឹត្តទៅនៅទីក្រុងប៊ូសានសាធារណៈរដ្ឋកូរ៉េ នៅឆ្នាំ២០១៤ កិច្ចប្រជុំបានអនុម័តនូវផែនការយុទ្ធសាស្ត្រសម្រាប់សហភាពទូរគមនាគមន៍អន្តរជាតិឆ្នាំ២០១៦-២០១៩ និងរបៀបវារៈនៃការតភ្ជាប់នៅឆ្នាំ២០២០ សម្រាប់ការអភិវឌ្ឍវិស័យ **ទ-ប.គ.ព.** ដែលក្នុងនោះបណ្តាប្រទេសជាសមាជិកសន្យាជំរុញកំណើននៃការទទួលបានការប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន, ការបង្កើតនូវបរិយាកាសវិជ្ជមានលើការទទួលបានការប្រើប្រាស់នេះសម្រាប់ការអភិវឌ្ឍសង្គមនិងសេដ្ឋកិច្ច ដោយត្រូវគិតពិចារណាលើគ្រប់តួអង្គពាក់ព័ន្ធទាំងអស់, ការជំរុញការចូលរួមកាត់បន្ថយគម្លាតឌីជីថលនិងជួយសម្រួលដល់ប្រជាជនដែលងាយរងគ្រោះ, ការជំរុញនវានុវត្តន៍ និងភាពជាដៃគូ។

ទន្ទឹមនេះ នៅក្នុងក្របខ័ណ្ឌនៃកិច្ចសហប្រតិបត្តិការថ្នាក់តំបន់អាស៊ី-ប៉ាស៊ីហ្វិក នាអំឡុងពេលប៉ុន្មានឆ្នាំចុងក្រោយតំបន់អាស៊ី-ប៉ាស៊ីហ្វិកទទួលបាននូវការអភិវឌ្ឍជាច្រើនគួរឱ្យកត់សម្គាល់ពាក់ព័ន្ធនឹងហេដ្ឋារចនាសម្ព័ន្ធអ៊ិនធឺណិតល្បឿនលឿននិងសេវា។ ក៏ប៉ុន្តែ គម្លាតឌីជីថលជាពិសេសការប្រើប្រាស់អ៊ិនធឺណិតល្បឿនលឿននៅតែជាចំណោទបញ្ហាធ្ងន់ធ្ងរ។ ការអភិវឌ្ឍវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន (**ប.គ.ព.**) ក្នុងចំណោមបណ្តាប្រទេសជាសមាជិកនៅមានកម្រិតនៅឡើយ ជាពិសេសចំពោះបណ្តាប្រទេសអភិវឌ្ឍតិចតួច ប្រទេសកំពុងអភិវឌ្ឍគ្មានព្រំប្រទល់ជាប់សមុទ្រ និងរដ្ឋកំពុងអភិវឌ្ឍដែលជាកោះតូចៗ។ ដើម្បីដោះស្រាយនូវចំណោទបញ្ហាខាងលើ សហគមទូរគមនាគមន៍អាស៊ី-ប៉ាស៊ីហ្វិក បានអនុម័តនូវផែនការយុទ្ធសាស្ត្រសម្រាប់ឆ្នាំ២០១៥-២០១៧ ដែលបានផ្តោតទៅលើការកសាងសេដ្ឋកិច្ចឌីជីថលឆ្លាតវៃ តាមរយៈការប្រើប្រាស់ **ប.គ.ព.** នៅតំបន់អាស៊ី-ប៉ាស៊ីហ្វិក ដើម្បីធានានូវការសម្រេចឱ្យបាននូវការអភិវឌ្ឍប្រកបដោយចីរភាពនិងការលើកកម្ពស់គុណភាពជីវភាពរបស់ប្រជាជននៅក្នុងតំបន់, តាមរយៈការរៀបចំបរិស្ថានគោលនយោបាយនិងបទប្បញ្ញត្តិ ដើម្បីបង្កើតសេដ្ឋកិច្ចឌីជីថលថ្មី, និងការរៀបចំកម្មវិធីនៃការកសាងសមត្ថភាព។

ដោយឡែកនៅក្នុងក្របខ័ណ្ឌអាស៊ាន វិស័យ **ប.គ.ព.** ដើរតួនាទីយ៉ាងសំខាន់ក្នុងការគាំទ្រលើសមាហរណកម្មតំបន់និងការតភ្ជាប់។ វិស័យ **ប.គ.ព.** ជាពិសេសអ៊ិនធឺណិត បាននិងកំពុងក្លាយជាចំណែកសំខាន់មួយនៃការកសាងសហគមន៍និងសមាហរណកម្មសេដ្ឋកិច្ចអាស៊ាន ព្រមទាំងបានចូលរួមការអភិវឌ្ឍនិងកំណើននៃគ្រប់ទិដ្ឋភាពទាំងអស់នៃសង្គមនិងសេដ្ឋកិច្ច។ នាពេលបច្ចុប្បន្ន អាស៊ានកំពុងស្ថិតនៅក្នុងស្ថានភាពអន្តរកាលឆ្ពោះទៅការកសាងសហគមន៍សេដ្ឋកិច្ចឌីជីថល។ ផែនការមេបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានអាស៊ាន២០១៥ ទទួលបាននូវការអនុវត្តប្រកបដោយជោគជ័យពីបណ្ដារដ្ឋសមាជិកអាស៊ាន ដែលមានយុទ្ធសាស្ត្រគន្លឹះ ចំនួន៦ គឺ ការផ្លាស់ប្ដូរសេដ្ឋកិច្ច, ការផ្ដល់អំណាចដល់ប្រជាជន, ការកសាងហេដ្ឋារចនាសម្ព័ន្ធ, នវានុវត្តន៍, ការកសាងសមត្ថភាព និងការកាត់បន្ថយគម្លាតឌីជីថល។ ការរៀបចំនូវផែនការមេបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានអាស៊ាន២០២០ ដែលត្រូវបានប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការនៅឆ្នាំ២០១៥ ផ្ដោតជាចម្បងលើការផ្លាស់ប្ដូរយ៉ាងទូលាយលើវិស័យសេដ្ឋកិច្ច ជាពិសេសផ្ដោតទៅលើការផ្លាស់ប្ដូរសេដ្ឋកិច្ចអាស៊ានទៅជាសេដ្ឋកិច្ចឌីជីថល។ សេដ្ឋកិច្ចឌីជីថល ក្នុងន័យនៃផែនការមេនេះ សំដៅទៅលើសេដ្ឋកិច្ចដែលមានមូលដ្ឋានផ្អែកលើបណ្ដុំនៃជំនាញជាក់លាក់ ដែលមានទេពកោសល្យ, កិច្ចសម្រួលសមាហរណកម្មទីផ្សារដែលមានភាពទាក់ទាញសម្រាប់ការវិនិយោគ និងការកសាងបរិស្ថានឌីជីថលប្រកបដោយសុវត្ថិភាពនិងភាពជឿជាក់។ យុទ្ធសាស្ត្រគន្លឹះដែលត្រូវបានកំណត់នៅក្នុងផែនការមេថ្មីនេះមានចំនួន៨ គឺ ***ទី១.*** ការផ្លាស់ប្ដូរនិងការអភិវឌ្ឍសេដ្ឋកិច្ច, ***ទី២.*** ការផ្ដល់អំណាចនិងសមាហរណកម្មប្រជាជនតាមរយៈ **ប.គ.ព.**, ***ទី៣.*** នវានុវត្តន៍, ***ទី៤.*** ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ **ប.គ.ព.**, ***ទី៥.*** ការអភិវឌ្ឍធនធានមនុស្ស, ***ទី៦.*** **ប.គ.ព.** នៅក្នុងទីផ្សារតែមួយរបស់អាស៊ាន, ***ទី៧.*** មាតិកានិងប្រព័ន្ធផ្សព្វផ្សាយថ្មី, និង ***ទី៨.*** ការធានានិងសន្តិសុខព័ត៌មាន។

ស្របតាមផែនការយុទ្ធសាស្ត្រនានាដែលត្រូវបានដាក់ចេញនៅថ្នាក់តំបន់និងពិភពលោកខាងលើ ការអភិវឌ្ឍវិស័យ **ទ-ប.គ.ព.** សម្រាប់កម្ពុជា គឺជាឧបករណ៍នយោបាយប្រកបដោយប្រសិទ្ធភាពសម្រាប់ការបង្កើតនូវក្របខ័ណ្ឌមួយដែលចូលរួមអភិវឌ្ឍគ្រប់ទិដ្ឋភាពនៃសង្គមនិងសេដ្ឋកិច្ចនាពេលអនាគត។ វិស័យ **ទ-ប.គ.ព** រួមចំណែកសំខាន់ដល់ការផ្លាស់ប្ដូរក្របខ័ណ្ឌសង្គមនិងសេដ្ឋកិច្ចរបស់កម្ពុជា តាមរយៈការបង្កើតបរិយាកាសវិនិយោគប្រកបដោយភាពទាក់ទាញ, ការបង្កើតការងារ, ការបង្កើនប្រាក់ចំណូល និងការលើកកម្ពស់ផលិតភាពតាមរយៈការទទួលបាននូវបច្ចេកវិទ្យាថ្មីៗ រួមទាំងការបង្កើតការងារក្នុងវិស័យគាំទ្រឧស្សាហកម្មដទៃទៀត ជាអាទិ៍ ខ្សែចង្វាក់តម្លៃចាប់តាំងពីការផលិតនិងការផ្គត់ផ្គង់វត្ថុធាតុដើម, សេវាដឹកជញ្ជូននិងឡូជីស្ទីក, វិស័យហិរញ្ញវត្ថុ និងបណ្ដុះបណ្ដាលជំនាញ ជាដើម។

ក្រៅពីនេះ គោលនយោបាយនេះ ត្រូវបានរៀបចំនិងធ្វើឡើង ដើម្បីឆ្លើយតបទៅនឹងការដាក់ចេញនូវវិធានការជាអាទិភាពមួយក្នុងចំណោមវិធានការទាំងឡាយរបស់រាជរដ្ឋាភិបាលកម្ពុជា នាអាណត្តិទី៥ ដើម្បីបន្តចូលរួមអភិវឌ្ឍ **ប.គ.ព.** ឱ្យមានលក្ខណៈទំនើប ទាន់សម័យ មានគុណភាពខ្ពស់ស្របតាមស្តង់ដាអន្តរជាតិ មានថ្លៃប្រកួតប្រជែង និងមានសេវាគ្របដណ្ដប់ទូទាំងប្រទេសដែលប្រជាជនទូទៅអាចប្រើប្រាស់បាន និងទទួលបានផលប្រយោជន៍គ្រប់ៗគ្នាពីសេវានេះ។

ជាការសន្និដ្ឋាន ការរៀបចំនិងការដាក់ចេញនូវគោលនយោបាយអភិវឌ្ឍន៍វិស័យ **ទ-ប.គ.ព** នេះឡើង គូសបញ្ជាក់ អំពីភាពចាំបាច់និងភាពបន្ទាន់ក្នុងការបង្កើតនូវ ***«យុទ្ធសាស្ត្រផ្លាស់ប្ដូរមូលដ្ឋានសេដ្ឋកិច្ចថ្មី»*** ដែលឆ្លើយតបទៅនឹងការប្រែប្រួលសេចក្ដីត្រូវការក្នុងស្រុកនិងសភាពការណ៍ថ្នាក់តំបន់និងពិភពលោក ដែលកំពុងវិវត្តឥតឈប់ឈរ និងឆាប់រហ័ស។

### ១.២)-**ការផ្សារភ្ជាប់វិស័យទូរគមនាគមន៍និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន** (ប.គ.ព.)

ការសម្រេចបញ្ចូលនូវវិស័យទាំងទូរគមនាគមន៍និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ដាក់ទៅក្នុងគោលនយោបាយតែមួយ ត្រូវបានធ្វើឡើងដោយផ្អែកលើមូលដ្ឋានមួយចំនួន ជាអាទិ៍ ៖

**ទី១.និយមន័យឬសញ្ញាណនៃបច្ចេកស័ព្ទទូរគមនាគមន៍និង ប.គ.ព.** ផ្អែកតាមច្បាប់ស្តីពីទូរគមនាគមន៍ បច្ចេកស័ព្ទ **ទូរគមនាគមន៍**នេះ សំដៅទៅលើវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាក្នុងការបញ្ជូន និងទទួលស៊ីញ៉ាល់ ទិន្នន័យ សំឡេង រូបភាព ឬប្រភពព័ត៌មានដទៃទៀត តាមរយៈការប្រើប្រាស់ថាមពលក្រោមទម្រង់អេឡិកត្រូម៉ាញេទិក អគ្គិសនី វិទ្យុ ពន្លឺឬទម្រង់ដទៃទៀត។ ចំណែក **ប.គ.ព.** ក្នុងន័យនៃគោលនយោបាយនេះ សំដៅលើបច្ចេកវិទ្យាទាំងឡាយណាដែលគ្រប់គ្រង និងដាក់ឱ្យដំណើរការព័ត៌មាន។ បច្ចេកវិទ្យាទាំងនោះរួមមានវិទ្យុ ទូរទស្សន៍ ទូរស័ព្ទ ឧបករណ៍បណ្តាញ ប្រព័ន្ធផ្កាយរណប សូហ្វវែរឬសូហ្វែរកម្មវិធីជាច្រើនទៀត។ល។ ក្នុងនិម្មាបនកម្មនៃបណ្តាញទំនើប បច្ចេកស័ព្ទ **ប.គ.ព.** គឺជាបច្ចេកស័ព្ទដែលមានលក្ខណៈទូលាយ ដែលបញ្ជាក់នូវតួនាទីនៃគមនាគមន៍រួម (Unified Communications) និងប្រព័ន្ធទូរគមនាគមន៍ (Integration of telecommunications) កុំព្យូទ័រ សូហ្វវែរ ការផ្ទុក និងប្រព័ន្ធរូបភាពនិងវីដេអូ។ តាមន័យសាមញ្ញ **ប.គ.ព.** សំដៅទៅលើការផ្សំគ្នានូវរូបភាព-វីដេអូ និងបណ្តាញទូរស័ព្ទ ជាមួយនឹងបណ្តាញកុំព្យូទ័រ តាមរយៈខ្សែកាប្លិ៍មួយឬប្រព័ន្ធតភ្ជាប់។ ដូច្នេះ ការវិវត្តនៃការប្រើប្រាស់បច្ចេកស័ព្ទទាំងពីរនេះ បង្ហាញនូវទំនាក់ទំនងយ៉ាងជិតស្និទ្ធ និងមិនអាចកាត់ផ្តាច់គ្នាបានតាមលក្ខណៈវិទ្យាសាស្ត្រ ជាពិសេសនិន្នាការនិងការវិវត្តនៃបច្ចេកវិទ្យាដែលមានលក្ខណៈជឿនលឿន នាំឱ្យបណ្តាប្រទេសអភិវឌ្ឍន៍មួយចំនួនទទួលស្គាល់នូវឧត្តមភាពនៃ **ប.គ.ព.** និងស្ទើរតែឈប់ប្រើបច្ចេកស័ព្ទទូរគមនាគមន៍នៅក្នុងក្របខ័ណ្ឌគោលនយោបាយរបស់ខ្លួន។

**ទី២.សមាជិកភាពរបស់កម្ពុជាទៅក្នុងសហគមន៍ទូរគមនាគមន៍អាស៊ី-ប៉ាស៊ីហ្វិកនិងសហភាពទូរគមនាគមន៍អន្តរជាតិ៖** ថ្វីត្បិតតែអង្គការទាំងពីរនេះប្រើប្រាស់នូវបច្ចេកស័ព្ទទូរគមនាគមន៍នៅក្នុងឈ្មោះរបស់ខ្លួនក៏ដោយ នៅក្នុងគ្រប់ឯកសារគោលនយោបាយនិងយុទ្ធសាស្ត្រ ដែលត្រូវបានដាក់ចេញដោយអង្គការទាំងពីរនេះ តែងតែប្រើបច្ចេកស័ព្ទ **ទូរគមនាគមន៍និង ប.គ.ព.** នៅជាមួយគ្នាជានិច្ច។ កម្ពុជា ក្នុងនាមជាសមាជិក បានភ្ជាប់ការសន្យាមួយចំនួន ក្នុងការឈានទៅរកការសម្រេចឱ្យបាននូវការដាក់ចេញគោលដៅមួយចំនួន ជាអាទិ៍ ក្របខ័ណ្ឌនៃការតភ្ជាប់ឆ្នាំ២០២០ និងការប្រើប្រាស់ទូរគមនាគមន៍និង **ប.គ.ព. ដើម្បីចូលរួមការអភិវឌ្ឍប្រកបដោយចីរភាព។**

**ទី៣. សមាហរណកម្មរបស់កម្ពុជាទៅក្នុងសហគមន៍អាស៊ាន៖** ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ត្រូវបានកំណត់ជាកាលបរិច្ឆេទនៃការសម្រេចបាននូវសមាហរណកម្មសហគមន៍សេដ្ឋកិច្ចអាស៊ាន។ វិស័យទូរគមនាគមន៍និង **ប.គ.ព.** ជាវិស័យមួយស្ថិតនៅក្រោមសហគមន៍នេះ។ កាលពីខែវិច្ឆិកា ឆ្នាំ២០១៥ រដ្ឋមន្ត្រីទូរគមនាគមន៍និងព័ត៌មានវិទ្យាអាស៊ានបានប្រជុំគ្នាដើម្បីធ្វើការប្រកាសនិងដាក់ចេញនូវក្របខ័ណ្ឌនៃគោលនយោបាយថ្មី គឺផែនការមេបច្ចេកវិទ្យាគមនាគមន៍អាស៊ានឆ្នាំ២០២០ ដើម្បីចូលរួមជំរុញការប្រើប្រាស់ **ប.គ.ព.** ក្នុងន័យឈានទៅរកការសម្រេចឱ្យបាននូវកំណើនសេដ្ឋកិច្ច ការបែងចែកកំណើនសេដ្ឋកិច្ចប្រកបដោយសមធម៌និងការកាត់បន្ថយគម្លាតរវាងរដ្ឋសមាជិកអាស៊ានចាស់និងថ្មី។

**ទី៤. និន្នាការនិងការវិវត្តនៃការរៀបចំស្ថាប័នទទួលបន្ទុកលើវិស័យទាំងពីរនេះ៖** នៅក្នុងបណ្តាប្រទេសនៅក្នុងតំបន់អាស៊ាន សហគមន៍ទូរគមនាគមន៍អាស៊ី-ប៉ាស៊ីហ្វិក និងសហភាពទូរគមនាគមន៍អន្តរជាតិ ការប្រើប្រាស់ឈ្មោះ

ស្ថាប័នទទួលបន្ទុកដោយរក្សាទុកតែទូរគមនាគមន៍ត្រូវបានកាត់បន្ថយយ៉ាងច្រើន។ នៅក្នុងអាស៊ាន មានតែប្រទេសកម្ពុជានិងប្រទេសឡាវប៉ុណ្ណោះ ដែលមានក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។ នៅអាស៊ី-ប៉ាស៊ីហ្វិកនិងនៅលើពិភពលោក ឈ្មោះនេះត្រូវបានប្រើប្រាស់តែដោយប្រទេសកំពុងអភិវឌ្ឍប៉ុណ្ណោះ។ ក្នុងន័យនេះ ការអភិវឌ្ឍវិស័យទូរគមនាគមន៍និង **ប.ឥ.៧**. ចូលរួមចំណែកយ៉ាងសំខាន់ក្នុងការនាំឱ្យប្រទេសមួយឈានទៅរកចំណាត់ថ្នាក់ថ្មីនៅក្នុងតំបន់និងនៅលើពិភពលោក។

ជាការសន្និដ្ឋាន ការបញ្ចូលគ្នានូវវិស័យទាំងពីរនេះ គឺជាការសម្របខ្លួនរបស់កម្ពុជានាពេលអនាគត ទៅនឹងការធានានូវការសម្រេចឱ្យបាននូវការសន្យារបស់កម្ពុជាទៅក្នុងសុខដុមនីយកម្មថ្នាក់តំបន់ដែលមានអាស៊ាននិងសហគមន៍ទូរគមនាគមន៍អាស៊ី-ប៉ាស៊ីហ្វិក និងថ្នាក់ពិភពលោកដែលមានសហភាពទូរគមនាគមន៍អន្តរជាតិ។ ជាលទ្ធផលការប្រកាសឱ្យប្រើដោយរាជរដ្ឋាភិបាលកម្ពុជានូវគោលនយោបាយនេះ នឹងនាំឱ្យមានការរៀបចំនូវរចនាសម្ព័ន្ធដឹកនាំសម្របសម្រួលប្រកបដោយប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព និងគណនេយ្យភាព ដើម្បីអនុវត្តវិធានការយុទ្ធសាស្ត្រនានាដែលមានចរិតលក្ខណៈអន្តរវិស័យ។

## ២)-ស្ថានភាពនៃការអភិវឌ្ឍវិស័យទូរគមនាគមន៍-បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន (ទ-ប.គ.ព.) នៅកម្ពុជា

ស្របតាមគោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលនីតិកាលទី៤ និងនីតិកាលទី៥ ក៏ដូចជាក្នុងគោលដៅត្រៀមរៀបចំមូលដ្ឋានសម្រាប់ការឈានឡើងរបស់កម្ពុជាទៅកាន់ដំណាក់កាលថ្មីនៃការអភិវឌ្ឍ ពិសេសការធានាភាពប្រកួតប្រជែងរបស់កម្ពុជានៅក្នុង **«សេដ្ឋកិច្ចឌីជីថល»** នាពេលអនាគត រាជរដ្ឋាភិបាលកម្ពុជាបន្តជំរុញការអភិវឌ្ឍ **ប.គ.ព.** ឱ្យមានលក្ខណៈទំនើប, ទាន់សម័យ មានគុណភាពខ្ពស់ស្របតាមស្តង់ដាអន្តរជាតិ, មានថ្លៃប្រកួតប្រជែង និងមានសេវាគ្របដណ្តប់នៅទូទាំងប្រទេស ដែលប្រជាជនទូទៅអាចប្រើប្រាស់បាន និងទទួលបានផលប្រយោជន៍គ្រប់ៗគ្នាពីសេវានេះតាមរយៈការពង្រឹងក្របខ័ណ្ឌគតិយុត្ត, ការកសាងសមត្ថភាពស្ថាប័ន, ការធ្វើទំនើបកម្មមូលដ្ឋានសម្ភារៈបច្ចេកទេស, ការពង្រឹងប្រសិទ្ធភាពនៃការប្រើប្រាស់ **ប.គ.ព.** និងរដ្ឋបាលអេឡិចត្រូនិក ព្រមទាំងការជំរុញសាងសង់និងបង្កើនប្រសិទ្ធភាពនៃហេដ្ឋារចនាសម្ព័ន្ធឆ្អឹងខ្នងសម្រាប់វិស័យ **ប.គ.ព.**។

ដើម្បីឆ្លើយតបទៅនឹងគោលដៅនេះ រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចនូវសមិទ្ធផលសំខាន់ៗជាច្រើន និងបន្តជួបប្រទះនូវបញ្ហាប្រឈមមួយចំនួន ដែលយើងអាចប្រមូលផ្តុំបានកត្តាចម្បងៗចំនួនបី គឺ **២.១)**-កត្តាមូលដ្ឋានគ្រឹះទ្រទ្រង់វិស័យនេះនៅមានកម្រិត, **២.២)**-កត្តាកម្មញភាព **ប.គ.ព.**, និង**២.៣)**-កត្តានៃការប្រើប្រាស់សូហ្វវែរកម្មវិធី។

### ២.១)-កត្តាមូលដ្ឋានគ្រឹះទ្រទ្រង់ការអភិវឌ្ឍវិស័យទូរគមនាគមន៍-បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន (ទ-ប.គ.ព.)

#### ក)-ក្របខ័ណ្ឌគតិយុត្តនិងស្ថាប័នសម្របសម្រួលបច្ចេកទេស

ការអភិវឌ្ឍក្របខណ្ឌគតិយុត្តពាក់ព័ន្ធនឹងវិស័យ **ទ-ប.គ.ព.** ត្រូវបានរាជរដ្ឋាភិបាលយកចិត្តទុកដាក់ និងបានដាក់បញ្ចូលទៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ (២០០៣-២០០៨) និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ (២០១៣-២០១៨)។ កន្លងមក រាជរដ្ឋាភិបាលកម្ពុជាបានរៀបចំសេចក្តីព្រាងច្បាប់ និងបទប្បញ្ញត្តិនានាជាច្រើនដើម្បីចូលរួមអភិវឌ្ឍវិស័យ **ទ-ប.គ.ព.** នេះ។ ជាលទ្ធផល ច្បាប់ស្តីពីទូរគមនាគមន៍ ច្បាប់ស្តីពីម៉ាកពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែល និងបទប្បញ្ញត្តិពាក់ព័ន្ធនានាត្រូវបានអនុម័តរួចរាល់។

ទោះជាមានភាពរីកចម្រើនគួរឱ្យកត់សម្គាល់ក្តី កម្ពុជានៅបន្តខ្វះចន្លោះក្របខ័ណ្ឌគោលនយោបាយនិងគតិយុត្តមួយចំនួនទៀតដើម្បីបន្តទ្រទ្រង់វិស័យនេះ ដើម្បីឆ្លើយតបទៅនឹងស្របតាមស្ថានភាពនិងនិន្នាការនៃការវិវត្តយ៉ាងឆាប់រហ័សខាងផ្នែកបច្ចេកវិទ្យា។ កង្វះខាតទាំងនោះរួមមាន៖

- ក្របខ័ណ្ឌគោលនយោបាយនិងគតិយុត្តដើម្បីធានាបាននូវប្រសិទ្ធភាព ស្ថិរភាព សន្តិសុខ និងភាពបន្សីគ្នានៃការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍និងការប្រើប្រាស់ **ប.គ.ព.** និងធានាបាននូវទំនុកចិត្តក្នុងការប្រើប្រាស់ ការទាក់ទាញការវិនិយោគ និងបង្កើនការប្រកួតប្រជែងលើវិស័យ **ទ-ប.គ.ព.** ក៏ដូចជាដើម្បីរក្សាបាននូវឧត្តមភាពប្រកួតប្រជែងរបស់កម្ពុជាក្នុងតំបន់ និងពិភពលោក។
- យន្តការនៃការគ្រប់គ្រង ត្រួតពិនិត្យ តាមដាន និងវាយតម្លៃលើការប្រើប្រាស់ធនធានទូរគមនាគមន៍កម្រជាអាទិ៍ វិសាលគមន៍ហ្វ្រេកង់សីវិទ្យុ ក្បាលលេខទូរគមនាគមន៍ អាសយដ្ឋានអេឡិចត្រូនិក និងអាសយដ្ឋាន

ឌីអិនអេស ដើម្បីធានានូវប្រសិទ្ធភាពនៃការប្រើប្រាស់ និងបរិយាប័ន្ននៃវិស័យ **ទ-ប.គ.ព.** ក្នុងការ កៀរគរចំណូលថវិកាជាតិ ព្រមទាំងសុខដុមនីយកម្មក្នុងតំបន់និងពិភពលោក ជាពិសេសសុខដុមនីយកម្ម នៃបន្ទារប្រេកង់វិទ្យុ ៧០០Mhz ស្របតាមនិន្នាការតំបន់និងពិភពលោក។

ក្រៅពីកង្វះក្របខ័ណ្ឌគតិយុត្តនេះ ការសម្របសម្រួលស្ថាប័នលើវិស័យ **ប.គ.ព.** នៅមានកម្រិតនៅឡើយ។ មុនឆ្នាំ២០១៤ ស្ថាប័នជំនាញចំនួនពីរទទួលខុសត្រូវក្នុងការសម្របសម្រួលនិងការអភិវឌ្ឍវិស័យ **ប.គ.ព.** គឺក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍និងអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍវិស័យ **ប.គ.ព.** (**អ.ប.គ.ព.**)។ កំណែទម្រង់របស់រាជរដ្ឋាភិបាលនីតិកាលទី៥បានធ្វើសមាហរណកម្ម **អ.ប.គ.ព.** ឱ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។ ជាលទ្ធផល ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ក្លាយជាស្ថាប័នជំនាញតែមួយគត់ដែលទទួលខុសត្រូវក្នុងការសម្របសម្រួលនិងអភិវឌ្ឍវិស័យនេះ។

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍មានតួនាទីគ្រប់គ្រងលើវិស័យប្រៃសណីយ៍ ទូរគមនាគមន៍ និងបច្ចេក-វិទ្យាគមនាគមន៍និងព័ត៌មាន និងមានតួនាទីសំខាន់ៗ ដូចជា ការបង្កើតគោលនយោបាយ ការគ្រប់គ្រងសហគ្រាសជាតិ និងការសម្របសម្រួលកិច្ចការអន្តរជាតិក្នុងវិស័យប្រៃសណីយ៍ ទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន។ ***ទោះជាយ៉ាងនេះក្តី កម្ពុជានៅមិនទាន់បានកំណត់ភារកិច្ចសម្របសម្រួលបច្ចេកទេស និងយន្តការការងារលម្អិតបន្ថែមដល់ក្រសួងនេះឱ្យបានជាក់លាក់នៅឡើយ ក្នុងការសម្របសម្រួលជាមួយក្រសួង-ស្ថាប័នផ្សេងទៀតនៅក្នុងក្របខ័ណ្ឌនៃការប្រើប្រាស់និងការរក្សាសន្តិសុខ ទ-ប.គ.ព. នៅក្នុងក្រសួង-ស្ថាប័នទាំងនោះ។ កង្វះយន្តការការងារក្នុងស្ថាប័នសម្របសម្រួលបង្កផលលំបាកដល់ការប្រើប្រាស់និងចំណាយខ្ជះខ្ជាយលើឧបករណ៍ហិរញ្ញវត្ថុបច្ចេកវិទ្យា និងសូហ្វវែរកម្មវិធី។ មិនត្រឹមតែប៉ុណ្ណោះ កម្ពុជាអាចនឹងត្រូវប្រឈមធ្ងន់ធ្ងរទៅនឹងការមិនអាចភ្ជាប់ទំនាក់ទំនងបានរវាងប្រព័ន្ធសូហ្វវែរកម្មវិធីដែលបានរៀបចំនិងប្រើប្រាស់ដាច់ដោយឡែកផ្សេងពីគ្នា ព្រមទាំងហានិភ័យផ្នែកសន្តិសុខទិន្នន័យនិងប្រព័ន្ធព័ត៌មានរបស់ក្រសួង-ស្ថាប័នផ្សេងៗនៅពេលខាងមុខ។***

**ខ)-ហេដ្ឋារចនាសម្ព័ន្ធនិងការប្រើប្រាស់សេវា ទ-ប.គ.ព.**

ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ **ទ-ប.គ.ព.** ក៏មិនខុសប្លែកពីហេដ្ឋារចនាសម្ព័ន្ធដទៃទៀតដែរសុទ្ធតែជាគន្លឹះដ៏សំខាន់សម្រាប់ទ្រទ្រង់កំណើនសេដ្ឋកិច្ច បង្កើនប្រសិទ្ធភាពសេដ្ឋកិច្ច ពិពិធកម្មសេដ្ឋកិច្ច និងពង្រឹងភាពប្រកួតប្រជែង។ ក្នុងស្មារតីនេះ រាជរដ្ឋាភិបាលអាណត្តិទី៥ នៅតែយកចិត្តទុកដាក់បន្តស្តារនិងកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដែលមានកំណត់ក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ ដែលក្នុងនោះ ការជំរុញសាងសង់និងបង្កើនប្រសិទ្ធភាពហេដ្ឋារចនា-សម្ព័ន្ធឆ្អឹងខ្នង **ទ-ប.គ.ព.** នៅតែជាគោលដៅយុទ្ធសាស្ត្រអាទិភាព។ គុណភាពបណ្តាញនិងសេវាត្រូវបានពង្រឹងជាលំដាប់ដោយសារការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធជាបន្តបន្ទាប់តាមរយៈប្រភពហិរញ្ញប្បទានសម្បទាននិងការវិនិយោគពីវិស័យឯកជន។ ជាក់ស្តែង ហេដ្ឋារចនាសម្ព័ន្ធបណ្តាញខ្សែកាប្លិ៍អុបទិកត្រូវបាននិងកំពុងពង្រីកវិសាលភាពគ្របដណ្តប់ទៅតាមបណ្តាខេត្តនិងតភ្ជាប់ជាមួយប្រទេសជិតខាង (វៀតណាម ឡាវ ថៃ)។ គិតត្រឹមដំណាច់ឆ្នាំ២០១៥ ហេដ្ឋារចនាសម្ព័ន្ធឆ្អឹងខ្នងបណ្តាញខ្សែកាប្លិ៍អុបទិកបានកើនដល់ ២៦.៤១១ គីឡូម៉ែត្រ ដែលកាលពីឆ្នាំ២០១០ មានប្រវែងត្រឹមតែ ២០.៣០០ គីឡូម៉ែត្រប៉ុណ្ណោះ។ ទន្ទឹមនេះ នាពេលបច្ចុប្បន្ន ក្រុមហ៊ុនចំនួនបី គឺក្រុមហ៊ុន TELCOTECH, ក្រុមហ៊ុន CHUAN WEI និងក្រុមហ៊ុន CFOCN បានទទួលអាជ្ញាបណ្ណស្ថាបនាបណ្តាញខ្សែកាប្លិ៍អុបទិកក្រោមបាតសមុទ្ររួចជាស្រេច ហើយក៏កំពុងរៀបចំផែនការអាជីវកម្មនិងត្រៀមលក្ខណៈដើម្បីឈានទៅអនុវត្តគម្រោងរបស់ខ្លួន។

ក្នុងចំណោមក្រុមហ៊ុនទាំងបីនេះ ក្រុមហ៊ុនចំនួនពីរ គឺក្រុមហ៊ុន TELCOTECH និងក្រុមហ៊ុន CFOCN បានចុះកិច្ចសន្យាសម្បទានជាមួយរាជរដ្ឋាភិបាលកម្ពុជាដើម្បីទទួលបានសិទ្ធិស្ថាបនា និងផ្តល់សេវាទូរគមនាគមន៍អន្តរជាតិតាមប្រព័ន្ធខ្សែកាប្លិ៍អុបទិកក្រោមបាតសមុទ្រនិងហេដ្ឋារចនាសម្ព័ន្ធពាក់ព័ន្ធនៅព្រះរាជាណាចក្រកម្ពុជា តាមទម្រង់ សាងសង់ ធ្វើម្ចាស់ អាជីវកម្ម និងផ្ទេរ។ តាមការគ្រោងទុក ក្រុមហ៊ុនទាំងពីរនេះនឹងបញ្ចប់ការស្ថាបនាហេដ្ឋារចនាសម្ព័ន្ធនេះ នៅដំណាច់ឆ្នាំ២០១៧។ ដោយឡែក ការចរចារៀបចំកិច្ចសន្យាសម្បទានជាមួយក្រុមហ៊ុន CHUAN WEI ជាមួយរាជរដ្ឋាភិបាលកម្ពុជាកំពុងដំណើរការ។ ភាគីទាំងសងខាងរំពឹងនឹងបញ្ចប់ការចរចានិងឈានដល់ការចុះកិច្ចសន្យានៅឆ្នាំ២០១៦នេះ។ នាពេលកន្លងមក រាជរដ្ឋាភិបាលកម្ពុជា បានផ្តល់សិទ្ធិដល់ក្រុមហ៊ុនចំនួន ៤ ប៉ុណ្ណោះ (រួមទាំងសហគ្រាសសាធារណៈរបស់រដ្ឋចំនួនមួយ) ដើម្បីកសាងចំណុចភ្ជាប់លើគោក (Landing Station)។ ក្រុមហ៊ុនទាំងបីខាងលើនេះ បានទទួលគោលការណ៍ពីរាជរដ្ឋាភិបាលរួចហើយ ក្នុងការកសាងចំណុចភ្ជាប់លើគោកនេះ។ ដូច្នេះ តាមរយៈការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនេះ ចាប់ពីឆ្នាំ២០១៨ កម្ពុជានឹងទទួលបាននូវសមត្ថភាពនិងល្បឿនការផ្តល់សេវាអ៊ិនធឺណិតប្រកបដោយគុណភាពនិងឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាជននៅក្នុងស្រុក។

ប៉ុន្តែទន្ទឹមនឹងវឌ្ឍនភាពដែលសម្រេចបានគួរឱ្យកត់សម្គាល់នេះ នាពេលបច្ចុប្បន្ន ហេដ្ឋារចនាសម្ព័ន្ធ **ឆ-ប.គ.ព.** នៅក្នុងប្រទេសកម្ពុជា នៅមានបញ្ហាមួយចំនួនដូចខាងក្រោម ៖

- *លំហូរចរាចរសេវាទូរគមនាគមន៍ និងសេវាអ៊ិនធឺណិតជាមួយអន្តរជាតិពឹងផ្អែកស្ទើរតែទាំងស្រុងលើហេដ្ឋារចនាសម្ព័ន្ធប្រទេសជិតខាង ដោយសារតែកម្ពុជាខ្វះបណ្តាញខ្សែកាប្លិ៍អុបទិកក្រោមបាតសមុទ្រនិងប្រព័ន្ធផ្កាយរណបដោយខ្លួនឯង ។*
- *ការអភិវឌ្ឍក្រោមរូបភាពប្រមូលផ្តុំដោយកន្លែង លើហេដ្ឋារចនាសម្ព័ន្ធឆ្អឹងខ្នងបណ្តាញខ្សែកាប្លិ៍អុបទិកនិងហេដ្ឋារចនាសម្ព័ន្ធគាំទ្រ ដែលធ្វើឱ្យវិសាលភាពនៃការអភិវឌ្ឍនេះមិនបានគ្របដណ្តប់ឱ្យបានគ្រប់ទិសទី នៅឡើយ។*
- *ការគ្រប់គ្រងការប្រើប្រាស់ធនធានទូរគមនាគមន៍កម្រដូចជាវិសាលគមន៍ប្រេកង់វិទ្យុ និងក្បាលលេខទូរគមនាគមន៍មិនទាន់មានប្រសិទ្ធភាពខ្ពស់ ដែលអាចអនុញ្ញាតឱ្យប្រើប្រាស់ធនធាននេះសម្រាប់ពង្រីកវិសាលភាពហេដ្ឋារចនាសម្ព័ន្ធ ឆ-ប.គ.ព.។*
- *ស្ថិរភាពហេដ្ឋារចនាសម្ព័ន្ធឆ្អឹងខ្នងបណ្តាញខ្សែកាប្លិ៍អុបទិកនៅមានកម្រិត។*
- *ហេដ្ឋារចនាសម្ព័ន្ធទ្រទ្រង់លើវិស័យដទៃទៀតដូចជាហេដ្ឋារចនាសម្ព័ន្ធព័ត៌មានជាតិមិនទាន់ត្រូវបានពង្រីកឱ្យបានទូលំទូលាយ។*

ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនាពេលកន្លងមក បានជំរុញធ្វើឱ្យកំណើននៃការប្រើប្រាស់សេវាមានសន្ទុះគួរឱ្យកត់សម្គាល់ដែលក្នុងនោះ អត្រានៃការលក់ស៊ីមកាតទូរស័ព្ទចល័តមានចំនួនប្រមាណ ២០,៨ លាន ស្មើនឹង ១៣៦% នៃចំនួនប្រជាជនសរុប នៅឆ្នាំ២០១៥ បើប្រៀបធៀបទៅនឹងឆ្នាំ២០០៨ មានចំនួនត្រឹមតែ ៣,៨ លាន ស្មើនឹង ២៨% ប៉ុណ្ណោះ។ ចំណែក អត្រានៃការជាវសេវាប្រើប្រាស់អ៊ិនធឺណិតមានចំនួនប្រមាណ ៦,៨ លាន ស្មើនឹង ៤៥% នៃចំនួនប្រជាជន នៅឆ្នាំ២០១៥ បើប្រៀបធៀបទៅនឹងឆ្នាំ២០០៨ មានចំនួនត្រឹមតែ ២ម៉ឺន ស្មើនឹង ០,១៥% ប៉ុណ្ណោះ។ បើទោះបីជាយ៉ាងនេះក៏ដោយ កង្វះខាតហេដ្ឋារចនាសម្ព័ន្ធនៅតែបន្តចាត់ទុកជាមូលហេតុសំខាន់ដែលបង្កឱ្យកើតមាន

គម្លាតឌីជីថលនៅក្នុងសង្គម។ គេនៅសង្កេតឃើញមានគម្លាតឌីជីថលកម្រិតខ្ពស់រវាងប្រជាជនទៅតាមទីជនបទនិងទីក្រុងដោយសារតែការប្រើប្រាស់សេវាទូរគមនាគមន៍ទាំងនោះមានភាគច្រើននៅតាមតំបន់ទីប្រជុំជន។ គម្លាតឌីជីថលនេះ បង្កឱ្យមានវិសមភាពនៃការទទួលបានឱកាសនិងផលប្រយោជន៍នានា ដែលផ្តល់ឱ្យដោយបច្ចេកវិទ្យានៅក្នុងសង្គម។ បញ្ហាហេដ្ឋារចនាសម្ព័ន្ធមិនទាន់ត្រូវបានពង្រីកឱ្យបានទូលំទូលាយគឺជាមូលហេតុមួយ ប៉ុន្តែនៅមានបញ្ហាចម្បងសំខាន់ៗផ្សេងទៀតដែលបង្កើតឱ្យមានគម្លាតឌីជីថលនេះឡើង ដូចជា៖

- ***ការខ្វះខាតការផ្គត់ផ្គង់អគ្គិសនីនៅតាមទីជនបទ។***
- ***កង្វះយន្តការលើកទឹកចិត្តដល់ការពង្រីកហេដ្ឋារចនាសម្ព័ន្ធដល់ទីជនបទ និងទីកន្លែងដែលគ្មានសក្តានុពលសេដ្ឋកិច្ច។***
- ***សេវាទូរស័ព្ទនិងអ៊ិនធឺណិតមានតម្លៃថ្លៃបើប្រៀបធៀបទៅនឹងប្រទេសដទៃទៀតក្នុងអាស៊ាន និងជាមួយប្រទេសដែលមានការអភិវឌ្ឍតិចតួចដទៃទៀត (ឧបសម្ព័ន្ធ៣ តារាងទី៣) ហើយបើប្រៀបធៀបទៅនឹងកម្រិតជីវភាពរបស់ប្រជាពលរដ្ឋទូទៅ។***
- ***ការបញ្ជ្រាបការប្រើប្រាស់ភាសាជាតិទៅក្នុងមាតិកាព័ត៌មាននិងសូហ្វវែរកម្មវិធីនានានៅមានកម្រិត។***

ក្រៅពីនេះ យើងសង្កេតឃើញមានគម្លាតឌីជីថលកម្រិតខ្ពស់ក្នុងវិស័យយេនឌ័រនិងជនងាយរងគ្រោះនានាដូចជាជនពិការ។ តាមការសិក្សាស្រាវជ្រាវរបស់ក្រសួងកិច្ចការនារីក្នុងឆ្នាំ២០១០ ក្នុងចំណោមបុគ្គលិកដែលចេះប្រើប្រាស់កុំព្យូទ័រនិងអ៊ិនធឺណិតក្នុងអង្គការសង្គមស៊ីវិល ក្រសួងស្ថាប័ន ក្រុមហ៊ុនឯកជន និងគ្រឹះស្ថានអប់រំនានា មានស្ត្រីសរុបជាមធ្យមត្រឹមតែ ២០.៤% ប៉ុណ្ណោះ។ គម្លាតឌីជីថលក្នុងវិស័យយេនឌ័រនេះ អាចជាឧបសគ្គនៃការអភិវឌ្ឍវិស័យទាំងមូលដោយហេតុថាក្នុងចំណោមប្រជាជនកម្ពុជាសរុបមានស្ត្រីប្រមាណ ៥១%។ ស្ត្រីមិនគ្រាន់តែជាកម្លាំងពលកម្មចម្បងក្នុងការងារប៉ុណ្ណោះទេ ស្ត្រីមានការចូលរួមចំណែកក្នុងការអភិវឌ្ឍសង្គមតាមបែបផ្សេងៗទៀត។ កង្វះខាតនូវចំណេះដឹងខាងផ្នែកបច្ចេកវិទ្យាគឺជាការកាត់បន្ថយឱកាសការងារ និងការចូលរួមផ្សេងៗរបស់ស្ត្រីទៅក្នុងសង្គម។ ផ្ទុយទៅវិញ ការបង្កើតនិងផ្តល់ឱកាសដល់ស្ត្រីបានចូលរួមក្នុងការអភិវឌ្ឍវិស័យ **ប.គ.ព.** និងការជំរុញការប្រើប្រាស់បច្ចេកវិទ្យានេះដើម្បីផ្តល់សិទ្ធិនិងសមភាពដល់ស្ត្រី គឺជាការអភិវឌ្ឍមួយប្រកបដោយចីរភាពនិងសមភាព។ ចំពោះជនពិការវិញ ការវិវត្តនៃបច្ចេកវិទ្យាជំនួយ (Assistive Technology) ទំនើបអាចជួយផ្តល់ឱកាសឱ្យពួកគេជម្នះលើពិការភាពរបស់ខ្លួន ធ្វើបរិយាប័ន្នទៅក្នុងសង្គមទូទៅ និងអនុញ្ញាតឱ្យគាត់អាចចូលរួមចំណែកក្នុងកិច្ចការសង្គមតាមផ្នែកផ្សេងៗជាច្រើន។ ប៉ុន្តែ កន្លងមកមានបញ្ហាជាច្រើនរាំងស្ទះដល់ការចូលរួមរបស់ស្ត្រី និងជនពិការនៅក្នុងវិស័យ **ប.គ.ព.** ដូចជាបរិបទវប្បធម៌ ឥរិយាបថ ទំនៀមទម្លាប់គ្រួសារដែលអនុញ្ញាតឱ្យកូនប្រុសរៀនបានច្រើនជាងកូនស្រី ឥរិយាបថនៃការគិតគូរលើការជ្រើសរើសជំនាញ ភាពខ្វះខាតចំណេះដឹងខាងភាសា ឥរិយាបថនៃការគិតគូរទៅលើជនពិការ។ល។ ប៉ុន្តែអ្វីដែលជាបញ្ហាចម្បងនោះគឺ ***កង្វះខាតការជំរុញការចូលរួមនិងការបង្កលក្ខណៈងាយស្រួលដល់ស្ត្រីនិងជនពិការក្នុងបរិបទវិស័យ ឌ-ប.គ.ព.។***

**គ)-អក្ខរកម្ម ប.គ.ព.**

អក្ខរកម្ម **ប.គ.ព.** គឺជាមូលដ្ឋានគ្រឹះសំខាន់មួយក្នុងការអភិវឌ្ឍវិស័យនេះ។ ការយល់ដឹងនិងការមានចំណេះដឹងក្នុងការប្រើប្រាស់បច្ចេកវិទ្យានេះ នឹងជំរុញឱ្យមានកំណើននៃការប្រើប្រាស់ **ប.គ.ព.** និងពង្រឹងការឆ្លើយតបរបស់ប្រជាពលរដ្ឋទៅនឹងទីផ្សារការងារនានាក្នុងពេលបច្ចុប្បន្ននិងអនាគត។

ក្នុងបរិបទទូទៅ ក្រសួងអប់រំ យុវជន និងកីឡា បានបង្កើតនូវ ***«គោលនយោបាយនិងយុទ្ធសាស្ត្រប្រើប្រាស់ ប.គ.ព. ក្នុងវិស័យអប់រំ២០០៤-២០០៨»*** ក្នុងគោលបំណងបង្កើនអក្ខរកម្ម បង្កើនជំនាញ ក៏ដូចជាដើម្បីប្រើប្រាស់ **ប.គ.ព.** ជាឧបករណ៍សម្រេចបានតាមទិសដៅ ***«ការអប់រំសម្រាប់ទាំងអស់គ្នា»***។ កម្មវិធីសិក្សា **ប.គ.ព.** ត្រូវបានដាក់បញ្ចូលទៅក្នុងកម្មវិធីសិក្សានានារបស់ក្រសួងអប់រំនាពេលកន្លងមក ដោយចាប់ផ្ដើមនៅតាមគ្រឹះស្ថានឧត្តមសិក្សា វិទ្យាស្ថានបណ្ដុះបណ្ដាលបច្ចេកទេស គ្រឹះស្ថានបណ្ដុះបណ្ដាលគ្រូនិងសាលាមធ្យមសិក្សាមួយចំនួន។ កម្មវិធីបណ្ដុះ-បណ្ដាលគ្រូបង្រៀននៅតាមសាលាគរុកោសល្យមួយចំនួនបានចាប់ផ្ដើមធ្វើឡើងតាំងពីឆ្នាំ២០០៣ និងកំពុងអនុវត្តជាបន្តបន្ទាប់។ សៀវភៅសិក្សាកុំព្យូទ័រ ***«បំណិនជីវិតបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន»*** ត្រូវបានរៀបចំឡើងជាភាសាខ្មែរសម្រាប់សិស្សថ្នាក់ទី១០ និងបានសម្រេចជាកម្មវិធីសិក្សាឯកភាពសម្រាប់ការបណ្ដុះបណ្ដាលពីការប្រើប្រាស់កុំព្យូទ័រនៅតាមវិទ្យាល័យ។ ***«ផែនការគោលស្ដីពីបច្ចេកវិទ្យាគមនាគមន៍ព័ត៌មាន និងសារគមនាគមន៍ក្នុងវិស័យអប់រំ ឆ្នាំ២០០៨-២០១៣»*** ត្រូវបានបង្កើតឡើងដើម្បីផ្ដួចផ្ដើមបញ្ចូលការប្រើប្រាស់ **ប.គ.ព.** ឱ្យបានកាន់តែទូលំទូលាយ លើកកម្ពស់ប្រសិទ្ធភាពនៃការអប់រំសម្រាប់ទាំងអស់គ្នា និងកសាងកម្លាំងពលករប្រកបដោយសមត្ថភាពខាង **ប.គ.ព.**។ មកទល់ឆ្នាំ២០១៣នេះ សាលារៀនប្រមាណ ៧% នៃសាលារៀនទូទាំងប្រទេសអាចប្រើប្រាស់អ៊ិនធឺណិតបាន។ ទោះជាមានកិច្ចខិតខំប្រឹងប្រែងលើកកម្ពស់កម្រិតអក្ខរកម្ម **ប.គ.ព.** ក្នុងចំណោមគ្រូបង្រៀននិងសិស្សានុសិស្សក៏ដោយ មានបញ្ហាចោទសំខាន់ចំនួនបីគឺ ***ទី១.កង្វះខាតគ្រូបង្គោលខាងផ្នែក ប.គ.ព. ទី២.កង្វះហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់ដូចជាបណ្ដាញអ៊ិនធឺណិតឱ្យបានទូលំទូលាយតាមសាលារៀន,*** និង ***ទី៣.កង្វះបរិក្ខារបច្ចេកវិទ្យាដូចជាកុំព្យូទ័រសម្រាប់បំពាក់តាមសាលារៀន ដែលបញ្ហាទាំងនេះត្រូវដោះស្រាយជាបន្ទាន់ដើម្បីបន្តផ្ដល់កម្មវិធីសិក្សាខាងផ្នែក ប.គ.ព.។***

ដោយឡែក នៅក្នុងជួរស្ថាប័នសាធារណៈ រាជរដ្ឋាភិបាលបានបញ្ជ្រាបការបង្កើនកម្រិតអក្ខរកម្ម **ប.គ.ព.** ដល់មន្ត្រីរាជការថ្នាក់កណ្ដាលនិងថ្នាក់មូលដ្ឋានតាមគម្រោងអភិវឌ្ឍន៍នានា។ នៅក្នុងឆ្នាំ២០០៨ មានមន្ត្រីរាជការថ្នាក់កណ្ដាលប្រមាណ៤០% ចេះប្រើប្រាស់កុំព្យូទ័រនិងសូហ្វវែរកម្មវិធីមូលដ្ឋាននានា ដូចជាសូហ្វវែរកម្មវិធីសម្រាប់ការងារការិយាល័យ អ៊ីម៉ែលនិងអ៊ិនធឺណិត។ រហូតមកដល់បច្ចុប្បន្នការបណ្ដុះបណ្ដាលមន្ត្រីរាជការត្រូវ បានធ្វើឡើងជាបន្តបន្ទាប់ទៅតាមតម្រូវជាក់ស្ដែងរបស់ក្រសួងស្ថាប័ននីមួយៗ។ ប៉ុន្តែ កម្ពុជានៅខ្វះការរៀបចំនិងអនុវត្តនូវ***ផែនការមេសម្រាប់បណ្ដុះបណ្ដាលមន្ត្រីរាជការគ្រប់ជាន់ថ្នាក់ដើម្បីឆ្លើយតបទៅនឹងបរិបទនៃការអភិវឌ្ឍរួមនិងការវិវត្តរបស់បច្ចេកវិទ្យា។***

### ២.២)-**កម្មញ្ញភាពបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន** (ប.គ.ព.)

### ក)-ប្រព័ន្ធសន្តិសុខ ឧ-ប.គ.ព.

កត្តាសន្តិសុខ **ឧ-ប.គ.ព.** គឺជាកត្តាចម្បងមួយក្នុងការអភិវឌ្ឍវិស័យ **ឧ-ប.គ.ព.** ដែលរាជរដ្ឋាភិបាលកម្ពុជាត្រូវយកចិត្តទុកដាក់និងមានការគិតគូរខ្ពស់។ សន្តិសុខ **ឧ-ប.គ.ព.** ជាកត្តាមួយដែលវាស់វែងអំពីភាពរួចរាល់របស់កម្ពុជាក្នុងការប្រើប្រាស់ **ប.គ.ព.** ដោយហេតុថាការគំរាមកំហែងបែបណាមួយទៅលើប្រព័ន្ធព័ត៌មាននៅយុគសម័យអ៊ិនធឺណិតនេះ គឺជាការគំរាមកំហែងដល់សន្តិសុខ សណ្ដាប់ធ្នាប់សង្គម និងសេដ្ឋកិច្ចជាតិទាំងមូល។

ការវាយប្រហារទៅលើប្រព័ន្ធ **ប.គ.ព.** បានកើតឡើងជាបន្តបន្ទាប់និងមានគោលបំណងដោយឡែកៗពីគ្នា ដែលមួយចំនួនមានការពាក់ព័ន្ធទៅនឹងរឿងនយោបាយ សេដ្ឋកិច្ច ឧក្រិដ្ឋកម្ម ភេរវកម្ម ចារកម្ម និងសន្តិសុខជាតិជាដើម។ រីឯឧបករណ៍ដែលប្រើប្រាស់និងបច្ចេកទេសសម្រាប់វាយប្រហារ មានលក្ខណៈកាន់តែទំនើប ពិបាកក្នុងការ

ការពារនិងទប់ស្កាត់។ នាពេលកន្លងមក មានការវាយប្រហារខ្នាតធំជាច្រើនកើតឡើងទៅលើហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗរបស់ប្រទេសមួយចំនួន ដូចជាការវាយប្រហារទៅក្នុងប្រព័ន្ធគ្រប់គ្រងរោងចក្រនុយក្លេអែររបស់ប្រទេសអ៊ីរ៉ង់ក្នុងឆ្នាំ២០១០, ការវាយប្រហារទៅលើប្រព័ន្ធចម្រោះទឹកស្អាតនៅសហរដ្ឋអាមេរិកដោយបានបង្អាក់ការផ្គត់ផ្គង់ទឹកមួយរយៈ, ការវាយប្រហារទៅលើប្រព័ន្ធរោងចក្រផលិតរថយន្តរបស់ប្រទេសជប៉ុន, ព្រឹត្តិការណ៍លួចលុយពីប្រព័ន្ធធនាគារប្រមាណពី៣០០ទៅ៩០០ លានដុល្លានៅលើពិភពលោកទាំងមូលដោយក្រុមអេឃ្វេសិន (Equation) ក្នុងឆ្នាំ២០១៥, និងការលួចឬបំផ្លាញទិន្នន័យរបស់អ្នកប្រើប្រាស់ជាង ៦០០ លានករណីជាដើម។ល។ ទន្ទឹមនឹងការវិវត្តទៅមុខឥតឈប់ឈររបស់បច្ចេកវិទ្យានេះ បញ្ហាសន្តិសុខនិងឯកជនភាពគឺជាចំណុចចម្បងមួយក្នុងចំណោមចំណុចជាច្រើននៃការព្រួយបារម្ភរបស់ឧស្សាហកម្ម **ប.ត.ព.**។

ការកើនឡើងនូវសកម្មភាពពាណិជ្ជកម្មនិងប្រតិបត្តិការហិរញ្ញវត្ថុតាមប្រព័ន្ធអ៊ិនធឺណិត ការដាក់ឱ្យប្រើប្រាស់នូវសេវារដ្ឋាភិបាលអេឡិកត្រូនិក, ប្រជាប្រិយភាពនៃការប្រើប្រាស់ប្រព័ន្ធបណ្តាញសង្គម, និងចរន្តនៃការវិវត្តទៅរកការប្រើប្រាស់ប្រព័ន្ធអ៊ិនធឺណិតនៃវត្ថុ ដែលមនុស្សនិងវត្ថុជាច្រើនត្រូវបានតភ្ជាប់ទៅនឹងប្រព័ន្ធអ៊ិនធឺណិត គឺជាកត្តាមួយដ៏សំខាន់ដែលជំរុញឱ្យមានការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម។ ទន្ទឹមនឹងនោះ សន្តិសុខនៅក្នុងការប្រើប្រាស់សេវា **ឌ-ប.ត.ព.** គឺជាបញ្ហាសំខាន់មួយដែលត្រូវមានការយកចិត្តទុកដាក់ខ្ពស់បំផុត ដើម្បីធានាឱ្យបាននូវផលវិជ្ជមានពីការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យានេះ។

នារយៈកាលកន្លងមក កម្ពុជាបានទទួលរងការវាយប្រហារជាច្រើនទៅលើគេហទំព័រស្ថាប័នរដ្ឋនិងស្ថាប័នធនាគារមួយចំនួន។ ដើម្បីឆ្លើយតបជាបន្ទាន់ទៅនឹងបញ្ហាអសន្តិសុខ **ឌ-ប.ត.ព.** រាជរដ្ឋាភិបាល បានសម្រេចគាំទ្រធ្វើយ៉ាងណាឱ្យសន្តិសុខនិងសុវត្ថិភាពក្នុងវិស័យ **ឌ-ប.ត.ព.** នៅកម្ពុជាកាន់តែមានភាពប្រសើរឡើងដូចមានចែងក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣។ រាជរដ្ឋាភិបាលបានបង្កើតមជ្ឈមណ្ឌលឆ្លើយតបទៅនឹងបញ្ហាបន្ទាន់នៃកុំព្យូទ័រ (CamCERT) ដើម្បីឆ្លើយតបទៅនឹងបញ្ហាបន្ទាន់នានាដែលទាក់ទងទៅនឹងសន្តិសុខ **ប.ត.ព.**។ កិច្ចប្រឹងប្រែងនេះបានធ្វើឱ្យភាពរួចរាល់របស់កម្ពុជាខាងផ្នែកសន្តិសុខព័ត៌មាន មានភាពប្រសើរឡើងជាលំដាប់។ ភាពរួចរាល់ផ្នែកសន្តិសុខព័ត៌មាននៅកម្ពុជាដែលត្រូវបានវាស់វែងក្នុងឆ្នាំ២០១៤ ដោយសហគមន៍ទូរគមនាគមន៍អន្តរជាតិ មានចំនួន០.១១៨ គឺស្មើនឹង១១.៨% ។ សន្ទស្សន៍នេះ បានមកពីការពិនិត្យលើជាតុមួយចំនួនដូចជាក្របខ័ណ្ឌគតិយុត្តអង្គភាពបច្ចេកទេស ស្ថាប័នសម្របសម្រួល ការបណ្តុះបណ្តាលសមត្ថភាព និងកិច្ចសហប្រតិបត្តិការ អន្តរជាតិលើវិស័យនេះ។ ទោះជាយ៉ាងណា អត្រានេះនៅមានកម្រិតទាបនៅឡើយ ហើយទាមទារឱ្យមានការខិតខំប្រឹងប្រែងគិតគូរអភិវឌ្ឍបន្តទៀត ដើម្បីសម្រេចបាននូវគោលដៅរួម ដែលស្នើឡើងដោយសហគមទូរគមនាគមន៍អន្តរជាតិ ក្នុងការបង្កើនភាពរួចរាល់ខាងផ្នែកសន្តិសុខ **ឌ-ប.ត.ព.** ក្នុងចំណោមប្រទេសជាសមាជិកក្នុងឆ្នាំ២០២០ឱ្យកើនឡើងដល់៤០%។

បច្ចុប្បន្នកម្ពុជាកំពុងប្រឈមនឹងបញ្ហាជាច្រើនទាក់ទងនឹងសន្តិសុខ **ឌ-ប.ត.ព.** ដូចជា***កង្វះក្របខ័ណ្ឌគតិយុត្ត កង្វះយន្តការសម្របសម្រួលថ្នាក់ជាតិលើផ្នែកសន្តិសុខ ឌ-ប.ត.ព. កង្វះស្តង់ដាសន្តិសុខ ឌ-ប.ត.ព. កង្វះប្រព័ន្ធត្រួតពិនិត្យផ្នែកសន្តិសុខ ឌ-ប.ត.ព. និងកង្វះយន្តការបញ្ជ្រាបការយល់ដឹងអំពីបញ្ហានេះដល់សាធារណជនជាដើម។*** ការដោះស្រាយបញ្ហាប្រឈមជាមូលដ្ឋានទាំងនេះ គឺជាភាពចាំបាច់បំផុតមួយដើម្បីធានាសម្រេចបាននូវគោលដៅខាងលើ។

ខ)-ឧស្សាហកម្ម ឧ-ប.គ.ព.

ឧស្សាហកម្ម **ឧ-ប.គ.ព.** ចម្បងនៅក្នុងប្រទេសកម្ពុជា គឺឧស្សាហកម្មផ្តល់សេវាទូរគមនាគមន៍និងអ៊ិនធឺណិត។ ឧស្សាហកម្មនេះបានចូលរួមចំណែកក្នុងកំណើនសេដ្ឋកិច្ចជាតិ ០,៤% នៅឆ្នាំ២០០៥ ហើយបន្តកើនឡើងយ៉ាងឆាប់រហ័សដល់ ៥,៥% ក្នុងឆ្នាំ២០១២។ គិតមកត្រឹមឆ្នាំ២០១៥ មានក្រុមហ៊ុនជាច្រើនរួមទាំងក្រុមហ៊ុនបរទេសផងចំនួន១០ បានវិនិយោគលើការផ្តល់សេវាទូរគមនាគមន៍ទាំងនេះ ហើយមានក្រុមហ៊ុនប្រមាណជា៣០ បានបើកផ្តល់សេវាអ៊ិនធឺណិត តែក្នុងចំណោមនោះមានក្រុមហ៊ុនតែ១៦ ប៉ុណ្ណោះបាននិងកំពុងដំណើរការជាក់ស្តែង។

ក្រៅពីឧស្សាហកម្មទូរគមនាគមន៍ កម្ពុជាមិនទាន់មានឧស្សាហកម្ម **ប.គ.ព.** សម្បូរបែបដទៃទៀតនៅឡើយ ហើយក៏មិនទាន់មានផែនការជាក់លាក់ណាមួយសម្រាប់ជំរុញការអភិវឌ្ឍវិស័យនេះស្របពេលដែលប្រទេសមួយចំនួនក្នុងតំបន់អាស៊ីអាគ្នេយ៍បានខិតខំប្រឹងប្រែងអភិវឌ្ឍ និងទទួលបានប្រយោជន៍ដ៏ធំធេងពីសេវានិងផលិតកម្មនានានៅក្នុងវិស័យនេះ ដែលមានដូចជា សេវាទូរគមនាគមន៍ សេវាអភិវឌ្ឍសូហ្វវែរកម្មវិធី ផលិតកម្មសម្ភារៈបរិក្ខារកុំព្យូទ័រ និងអេឡិកត្រូនិក និងសេវា **ប.គ.ព.** ដទៃទៀត។ ប្រទេសមួយចំនួននៅក្នុងអាស៊ានកំពុងផ្តោតការយកចិត្តទុកដាក់លើសេវាអភិវឌ្ឍសូហ្វវែរកម្មវិធី ដោយហេតុថា ទីផ្សារសូហ្វវែរនៅលើពិភពលោកកំពុងកើនឡើងជាលំដាប់ពីមួយឆ្នាំទៅមួយឆ្នាំ ហើយត្រូវបានភ្នាក់ងារលើកកម្ពស់ឧស្សាហកម្មព័ត៌មានវិទ្យាជាតិ(NIPA)របស់សាធារណរដ្ឋកូរ៉េខាងត្បូងប៉ាន់ស្មានថានឹងកើនដល់ ១៣ លានកោដិដុល្លាក្នុងឆ្នាំ២០១៥។

កម្ពុជាជាប្រទេសដែលមានសក្តានុពលសម្រាប់ការអភិវឌ្ឍនិងការទាក់ទាញវិនិយោគវិស័យឧស្សាហកម្ម ដោយសារមានកត្តាអំណោយផលជាច្រើនទាំងកត្តាក្នុងស្រុកនិងការវិវត្តថ្នាក់តំបន់និងពិភពលោកទាំងមូល។ ការទទួលបាននូវស្ថិរភាពនយោបាយ ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ទីតាំងភូមិសាស្ត្រអំណោយផល កំណើនយុវជនដែលជាកំលាំងពលកម្មសកម្មសម្រាប់វិស័យឧស្សាហកម្ម ព្រមទាំងការតាំងចិត្តកំណែទម្រង់របស់រដ្ឋាភិបាលដើម្បីកៀរគរការវិនិយោគ គឺជាភាពទាក់ទាញដល់ការវិនិយោគលើវិស័យឧស្សាហកម្ម ជាពិសេសឧស្សាហកម្ម **ប.គ.ព.**។ ប៉ុន្តែ កម្ពុជានៅមានបញ្ហាប្រឈមចម្បងមួយចំនួនដែលជាឧបសគ្គសម្រាប់ការអភិវឌ្ឍឧស្សាហកម្ម **ប.គ.ព.** នេះ។ ***បញ្ហាប្រឈមទាំងនោះមានចំនួនបី គឺ ទី១. ការខ្វះធនធានមនុស្សជំនាញទាំងបរិមាណនិងគុណភាព ទី២. ខ្វះស្តង់ដា ប.គ.ព. ហើយទី៣. ផ្នែកស្រាវជ្រាវ និងអភិវឌ្ឍន៍ក្នុងវិស័យនេះក៏នៅមានភាពទន់ខ្សោយនៅឡើយ។***

**ទី១.** កម្ពុជាត្រូវការចាំបាច់នូវធនធានមនុស្សទាំងបរិមាណនិងគុណភាពសម្រាប់ផ្គត់ផ្គង់តម្រូវការផលិត និងការផ្តល់សេវានានាក្នុងឧស្សាហកម្ម **ប.គ.ព.**។ ការអភិវឌ្ឍធនធានមនុស្សជំនាញ **ប.គ.ព.** កន្លងមក គឺជាបន្ទុករបស់គ្រឹះស្ថានឧត្តមសិក្សា។ ក្នុងផែនការគោលបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានក្នុងវិស័យអប់រំ ២០០៨-២០១៣ ក្រសួងអប់រំមានគោលបំណងអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈ បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ចាំបាច់សម្រាប់អ្នកបញ្ចប់ការសិក្សា ដើម្បីទទួលបានការងារធ្វើនៅក្នុងសង្គមដែលពឹងផ្អែកលើចំណេះដឹង។ ជាលទ្ធផលនៃកិច្ចប្រឹងប្រែងទាំងនេះ និស្សិតដែលបញ្ចប់ការសិក្សាជំនាញ **ប.គ.ព.** បានកើនឡើងពី ៧% នៃចំនួនសរុបក្នុងឆ្នាំ២០០៩ ដល់ចំនួនប្រមាណ ៨% ក្នុងឆ្នាំ២០១១។ ប៉ុន្តែ បរិមាណនៃធនធានមនុស្សនេះមិនអាចឆ្លើយតបទៅនឹងតម្រូវការទីផ្សារបានដោយសារគុណភាពមានកម្រិត។ តាមការវាយតម្លៃរបស់មជ្ឈមណ្ឌលបណ្តុះបណ្តាលប្រព័ន្ធព័ត៌មានក្នុងឆ្នាំ២០០៩ ថ្វីត្បិតបរិមាណនៃនិស្សិតដែលបញ្ចប់ការសិក្សាផ្នែកនេះ មានច្រើនជាងតម្រូវការជាក់ស្តែងប្រមាណ១.៦ដង ប៉ុន្តែចំនួននិស្សិតដែលមាន

គុណភាពការអនុវត្តការងារបាន គឺមានតិចតួចណាស់ហើយមិនអាចផ្គត់ផ្គង់គ្រប់លើតម្រូវការទាំងនោះទេ។ ជាក់ស្តែង ការធ្វើអង្កេតមួយនៅឆ្នាំ២០១៣ បានបង្ហាញថា និស្សិតដែលទើបបញ្ចប់ការសិក្សាផ្នែក **ប.គ.ព.** ចំនួន ៤៨.៣% មិនមានសមត្ថភាពគ្រប់គ្រាន់ក្នុងការធ្វើការងារជំនាញ។ ផែនការកំណែទម្រង់ប្រព័ន្ធអប់រំក្នុងនីតិកាលទី៥ មានគោលដៅធ្វើឱ្យប្រសើរឡើងនូវគុណភាពនៃការបង្រៀននិងការរៀន ដោយមានការកែលម្អប្រព័ន្ធប្រលងនិងកំណែទម្រង់កម្មវិធីសិក្សាដែលក្នុងនោះក៏មានការបញ្ចូលមុខវិជ្ជា **ប.គ.ព.** ទៅក្នុងកម្មវិធីសិក្សាទាំងនោះ និងការបណ្តុះបណ្តាលជំនាញ **ប.គ.ព.** តាមបណ្តាគ្រឹះស្ថានឧត្តមសិក្សានានា។ នេះបានបង្ហាញពីការតាំងចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការគិតគូរឡើងវិញទាំងបរិមាណនិងគុណភាព ដើម្បីផ្គត់ផ្គង់សេចក្តីត្រូវការក្នុងវិស័យ **ប.គ.ព.** និងការទាក់ទាញការវិនិយោគសម្រាប់បង្កើតការងារបន្ថែមលើវិស័យនេះ។

**ទី២.** ក្រៅពីបញ្ហាប្រឈមផ្នែកធនធានមនុស្ស កម្ពុជាក៏មិនទាន់មានប្រព័ន្ធផ្តល់ស្តង់ដាខាងផ្នែក **ឧ-ប.គ.ព.** ដែលទទួលស្គាល់ជាលក្ខណៈអន្តរជាតិនៅឡើយ។ ស្តង់ដានេះមានសារៈសំខាន់ណាស់ក្នុងការផ្តល់នូវភាពជឿជាក់លើផលិតផលនិងសេវាបច្ចេកវិទ្យា ហើយអាចជួយលុបបំបាត់នូវរបាំងបច្ចេកទេសខាងផ្នែកពាណិជ្ជកម្មផងដែរ។ ហេតុនេះការអភិវឌ្ឍស្តង់ដាខាងផ្នែក **ប.គ.ព.** គឺជាកត្តាមួយដ៏សំខាន់ក្នុងការទាក់ទាញការវិនិយោគនិងការអភិវឌ្ឍឧស្សាហកម្ម **ឧ-ប.គ.ព.** ឱ្យបានរីកចម្រើនប្រកបដោយចីរភាព។

**ទី៣.** កន្លងមកនេះ រាជរដ្ឋាភិបាលបានរៀបចំគោលនយោបាយ និងបទដ្ឋានគតិយុត្តនានា ដើម្បីជំរុញការស្រាវជ្រាវនិងការអភិវឌ្ឍ ជាអាទិ៍ ផែនការមេសម្រាប់ការស្រាវជ្រាវនិងការអភិវឌ្ឍនៅគ្រឹះស្ថានឧត្តមសិក្សា ២០១១-២០១៥ ផែនការមេវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា ២០១៤-២០២០ គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ២០១៥-២០២៥។ ទន្ទឹមនេះ នៅឆ្នាំ២០១៤ រាជរដ្ឋាភិបាលបានសម្រេចបង្កើតវិទ្យាស្ថានជាតិប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ដាក់ឱ្យស្ថិតនៅក្រោមដំបូលរបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។ វិទ្យាស្ថាននេះ ជាស្ថាប័នជាតិទីមួយដែលទទួលបន្ទុកបណ្តុះបណ្តាលនិងជំរុញការស្រាវជ្រាវនិងការអភិវឌ្ឍលើវិស័យទូរគមនាគមន៍និង **ប.គ.ព.** ។ ម្យ៉ាងវិញទៀត ច្បាប់ស្តីពីទូរគមនាគមន៍ បង្កើតមូលនិធិការកសាងសមត្ថភាពនិងការស្រាវជ្រាវនិងការអភិវឌ្ឍដែលទាមទារឱ្យប្រតិបត្តិករទូរគមនាគមន៍ និងបុគ្គលពាក់ព័ន្ធវិស័យទូរគមនាគមន៍ចូលរួមផ្តល់វិភាគទានចំនួន ១% នៃចំណូលសរុប គិតចាប់ពីឆ្នាំ២០១៧។

ទោះបីជាមានការរៀបចំគោលនយោបាយនិងបទដ្ឋានគតិយុត្តគាំទ្រលើការងារនេះ ការស្រាវជ្រាវនិងការអភិវឌ្ឍខាងផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា មិនទាន់បានពង្រឹងនៅឡើយ។ ការស្រាវជ្រាវនិងអភិវឌ្ឍន៍ខាងផ្នែក **ប.គ.ព.** ដែលជាកាតាលិករសំខាន់សម្រាប់ជំរុញដល់ការអភិវឌ្ឍឧស្សាហកម្ម **ប.គ.ព.** នៅមានកម្រិតនៅឡើយ ដោយសារការខ្វះខាតធនធានមនុស្ស យន្តការសម្របសម្រួល គោលនយោបាយ និងផែនការមេច្បាស់លាស់សម្រាប់ជំរុញការស្រាវជ្រាវនិងការអភិវឌ្ឍលើវិស័យនេះ។ ការវិនិយោគទៅលើការស្រាវជ្រាវខាងផ្នែកវិទ្យាសាស្ត្រនិងបច្ចេកវិទ្យានេះមានប្រមាណតែ ០.០៥% នៃផសស ក្នុងឆ្នាំ២០០៦ ហើយក្នុងចំណោមមនុស្ស១លាននាក់ មានអ្នកធ្វើការខាងផ្នែកស្រាវជ្រាវនិងការអភិវឌ្ឍប្រមាណតែ១៣នាក់ប៉ុណ្ណោះ។ ចំនួននេះនៅមានភាពតិចតួច បើប្រៀបធៀបទៅនឹងប្រទេសក្នុងតំបន់ ដូចជាប្រទេសថៃដែលមានការវិនិយោគលើផ្នែកនេះមានដល់ ០.២% នៃផសស ហ្វីលីពីនមាន ០.១% នៃផសស និងឥណ្ឌូនេស៊ីមាន០.១% នៃផសសក្នុងឆ្នាំ២០០៧។

## ២.៣)-កត្តានៃការប្រើប្រាស់សូហ្វវែរកម្មវិធី

### ក)-រដ្ឋាភិបាលអេឡិកត្រូនិកនិងពាណិជ្ជកម្មអេឡិកត្រូនិក

រាជរដ្ឋាភិបាលកម្ពុជាបានផ្តួចផ្តើមឱ្យមានការអភិវឌ្ឍនិងប្រើប្រាស់ប្រព័ន្ធរដ្ឋាភិបាលអេឡិកត្រូនិកសម្រាប់ជំនួយនិងបង្កើនប្រសិទ្ធភាពការងារតាមបណ្តាក្រសួង-ស្ថាប័នរដ្ឋចាប់តាំងពីឆ្នាំ២០០៣។ នាពេលនោះ រាជរដ្ឋាភិបាលកម្ពុជាបានកសាងហេដ្ឋារចនាសម្ព័ន្ធព័ត៌មានជាតិ និងបានបង្កើតសូហ្វវែរកម្មវិធីចំនួន០៤ គឺកម្មវិធីចុះបញ្ជីយានយន្ត កម្មវិធីចុះបញ្ជីដីធ្លី កម្មវិធីចុះបញ្ជីអ្នកស្នាក់នៅ និងប្រព័ន្ធសច្ចានុម័តអេឡិកត្រូនិក ហើយបានជំរុញការប្រើប្រាស់អ៊ីម៉ែល និងគេហទំព័រក្នុងក្រសួង-ស្ថាប័នទាំងនោះ។ ក្រៅពីនេះមានសូហ្វវែរកម្មវិធីជាច្រើនទៀតត្រូវបានបង្កើតឡើងនិងប្រើប្រាស់ជាបន្តបន្ទាប់នៅតាមបណ្តាក្រសួង-ស្ថាប័នរដ្ឋនានា ដូចជាកម្មវិធីចុះបញ្ជីស្លាកសញ្ញារបស់ក្រសួងពាណិជ្ជកម្ម ប្រព័ន្ធពន្ធដាររបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រព័ន្ធស្វ័យប្រវត្តិកម្មទិន្នន័យគយ និងប្រព័ន្ធគ្រប់គ្រងព័ត៌មានសុខាភិបាល ។ល។ តម្រូវការប្រើប្រាស់សូហ្វវែរកម្មវិធីបានកើនឡើងយ៉ាងឆាប់រហ័សពីមួយឆ្នាំទៅមួយឆ្នាំ និងមានការប្រែប្រួលទៅតាមការវិវត្តនិងស្ថានភាពជាក់ស្តែង។ តាមរយៈការផ្តល់ធាតុចូលរបស់ក្រសួង-ស្ថាប័នចំនួន០៧ តម្រូវការសូហ្វវែរកម្មវិធីសម្រាប់សម្រួលដល់ការងាររដ្ឋបាលនិងការងារជំនាញពាក់ព័ន្ធក្នុងឆ្នាំ២០១៦នេះ មានចំនួនសរុបរហូតដល់២៧ (សូមមើលឧបសម្ព័ន្ធទី៣ តារាងទី៤)។ បន្ថែមពីលើតម្រូវការសូហ្វវែរកម្មវិធីសម្រាប់សម្រួលការងារក្នុងក្រសួង-ស្ថាប័នផ្ទាល់ កម្ពុជាត្រូវការការអភិវឌ្ឍនូវសូហ្វវែរកម្មវិធីមួយចំនួនទៀតសម្រាប់ការធ្វើសមាហរណកម្មខ្លួនចូលទៅក្នុងសមាគមន៍សេដ្ឋកិច្ចអាស៊ានដូចជា ការអភិវឌ្ឍប្រព័ន្ធបញ្ចរតែមួយជាតិ កិច្ចសម្រួលពាណិជ្ជកម្ម និងដើម្បីឆ្លើយតបទៅនឹងសមាហរណកម្មសេដ្ឋកិច្ចអាស៊ាននៅឆ្នាំ២០១៥ ដោយកម្ពុជាត្រូវតភ្ជាប់ប្រព័ន្ធនេះទៅនឹងប្រព័ន្ធបញ្ចរតែមួយរបស់រដ្ឋជាសមាជិកអាស៊ានដទៃទៀត។

ស្របពេលដែលតម្រូវការនៃការប្រើប្រាស់ និងនិន្នាការផ្លាស់ប្តូរទៅរកការប្រើប្រាស់ប្រព័ន្ធរដ្ឋាភិបាលអេឡិកត្រូនិកនេះកាន់តែច្រើន កម្ពុជាអាចជួបប្រទះលើបញ្ហានៃការចំណាយខ្ជះខ្ជាយចំពោះការអភិវឌ្ឍសូហ្វវែរកម្មវិធីជាន់គ្នាពីក្រសួង-ស្ថាប័នមួយ ទៅក្រសួង-ស្ថាប័នមួយទៀតនិងការចំណាយខ្ជះខ្ជាយក្នុងរក្សាទុកទិន្នន័យក្នុងប្រព័ន្ធនិងនៅទីតាំងផ្សេងគ្នា។ ការអភិវឌ្ឍសូហ្វវែរកម្មវិធីទៅតាមលក្ខណៈដោយឡែកៗពីគ្នា ដោយគ្មានការកំណត់ក្របខ័ណ្ឌបច្ចេកទេសរួម នឹងចោទជាបញ្ហានាថ្ងៃអនាគតស្តីពី ***«ភាពមិនអាចប្រាស្រ័យទាក់ទងគ្នាបាន»*** នៃប្រព័ន្ធទាំងនោះ ហើយក៏នឹងក្លាយជាបញ្ហាចោទចម្បងលើប្រសិទ្ធភាពនិងភាពស័ក្តិសិទ្ធិក្នុងការការពារសន្តិសុខព័ត៌មាន ការឆ្លើយតបទៅនឹងការវាយប្រហារខាងផ្នែកបច្ចេកវិទ្យាទៅលើប្រព័ន្ធសូហ្វវែរកម្មវិធីនិងប្រព័ន្ធទិន្នន័យទាំងនោះ។ ***ស្ថានភាពទាំងអស់នេះ អាចកើតមានឡើងដោយសារការមិនទាន់មានការគិតគូរក្នុងរូបភាពទូលំទូលាយ ខ្វះផែនការមេច្បាស់លាស់ក្នុងការពង្រីកការប្រើប្រាស់ប្រព័ន្ធរដ្ឋាភិបាលអេឡិកត្រូនិក ការខ្វះចំណេះដឹងនៃការគ្រប់គ្រងប្រព័ន្ធនិងសូហ្វវែរកម្មវិធី និងជាពិសេសនោះគឺកង្វះស្ថាប័នសម្របសម្រួលបច្ចេកទេសលើការបង្កើតប្រព័ន្ធសូហ្វវែរកម្មវិធីទាំងនោះក្នុងចំណោមក្រសួង-ស្ថាប័នទាំងអស់។***

ក្រៅពីតម្រូវការសូហ្វវែរកម្មវិធី ការប្រើប្រាស់គេហទំព័រ និងអ៊ីម៉ែលសម្រាប់ទំនាក់ទំនង និងចែករំលែកព័ត៌មានអំពីស្ថាប័ននីមួយៗនៅក្នុងជួរស្ថាប័នរាជរដ្ឋាភិបាលថ្នាក់ជាតិ ក៏មានការកើនឡើងជាលំដាប់ដែរ។ ប៉ុន្តែ គេហទំព័រទាំងនោះមិនទាន់ត្រូវបានអភិវឌ្ឍន៍ឱ្យមានអន្តរអំពើជាមួយប្រជាពលរដ្ឋ សម្រាប់ផ្តល់សេវាសាធារណៈឱ្យបានល្អគ្រប់គ្រាន់នៅឡើយ។ កន្លងមក មិនមានការបង្កើតនូវក្របខ័ណ្ឌបច្ចេកទេសរួមណាមួយសម្រាប់អភិវឌ្ឍគេហទំព័រ និងការប្រើប្រាស់អ៊ីម៉ែលដែលមានស្តង់ដាត្រឹមត្រូវនៅក្នុងជួរក្រសួង-ស្ថាប័នរដ្ឋនោះឡើយ។ ស្ថានភាពបែបនេះបង្កើតឱ្យមាន

ហានិភ័យខ្ពស់ ស្តីពីបញ្ហាសន្តិសុខព័ត៌មាន និងការវាយប្រហារកែប្រែព័ត៌មានលើគេហទំព័រ ព្រមទាំងប្រព័ន្ធអ៊ីម៉ែល ទាំងនោះ។

ក្រៅពីប្រព័ន្ធរដ្ឋាភិបាលអេឡិកត្រូនិក ពាណិជ្ជកម្មអេឡិកត្រូនិកនៅក្នុងប្រទេសកម្ពុជា នៅមានភាពតូចចង្អៀត និងមិនគ្រប់លក្ខណៈនៅឡើយ។ ពាណិជ្ជកម្មអេឡិកត្រូនិកភាគច្រើនធ្វើឡើងតាមរបៀបប្រកាសលក់ទំនិញ ដោយបានត្រឹមតែបង្ហាញព័ត៌មានទំនិញតែមិនអាចទូទាត់ប្រាក់លើអ៊ិនធឺណិតបានទេ។ ការទិញទំនិញជាទូទៅត្រូវបានទូទាត់ប្រាក់នៅពេលដែលទំនិញដឹកទៅដល់កន្លែងឬត្រូវទូទាត់តាមរយៈការផ្ញើលុយតាមស្ថាប័នហិរញ្ញវត្ថុផ្សេងៗ។ការមិនអាចទូទាត់ប្រាក់នៅលើបណ្តាញអ៊ិនធឺណិតបាន គឺជារបាំងពាណិជ្ជកម្មមួយ ហើយកាត់បន្ថយឱកាសពាណិជ្ជកម្មរបស់កម្ពុជានៅលើទីផ្សារបើកចំហដ៏ធំរបស់ពិភពលោកទាំងមូល។

តាមរបាយការណ៍សេដ្ឋកិច្ចព័ត៌មានឆ្នាំ២០១៥ របស់សន្និសីទអង្គការសហប្រជាជាតិលើផ្នែកពាណិជ្ជកម្មនិងអភិវឌ្ឍន៍ កម្ពុជាមានតម្លៃសន្ទស្សន៍នៃភាពរួចរាល់នៃពាណិជ្ជកម្មអេឡិកត្រូនិកស្មើនឹង៣០,៨ ស្ថិតក្នុងចំណាត់ថ្នាក់លេខ៩២ ក្នុងចំណោម១៣០ប្រទេស នៅក្នុងឆ្នាំ២០១៤។ ***កម្ពុជាប្រឈមជាមួយបញ្ហាជាច្រើនដែលជាឧបសគ្គរាំងស្ទះដល់ការលូតលាស់នៃពាណិជ្ជកម្មអេឡិកត្រូនិក ដូចជាប្រព័ន្ធសន្តិសុខ ឲ.គ.ព. មិនទាន់រឹងមាំ ប្រព័ន្ធទូទាត់ប្រាក់តាមអ៊ិនធឺណិតមិនទាន់ដំណើរការនិងអត្រានៃការប្រើប្រាស់អ៊ិនធឺណិតនៅមានកម្រិតទាបនៅឡើយ។ ក្រៅពីនេះ កម្ពុជាមិនទាន់បានកសាងភាពជឿជាក់លើការទិញទំនិញនិងការទូទាត់ប្រាក់តាមប្រព័ន្ធអ៊ិនធឺណិតនៅឡើយ ដោយកម្ពុជាមិនទាន់មានច្បាប់ពាណិជ្ជកម្មអេឡិកត្រូនិក មិនទាន់មានហេដ្ឋារចនាសម្ព័ន្ធគន្លឹះសាធារណៈដើម្បីផ្តល់សេវាបញ្ជាក់សុវត្ថិភាពតាមប្រព័ន្ធអ៊ិនធឺណិត និងមិនទាន់មានច្បាប់ប្រឆាំងឧក្រិដ្ឋកម្មតាមប្រព័ន្ធ ឲ.គ.ព. សម្រាប់ដាក់ទោសទណ្ឌដល់អ្នកប្រព្រឹត្តបទឧក្រិដ្ឋតាមប្រព័ន្ធនេះ។*** ការដោះស្រាយបញ្ហាទាំងនេះនឹងពាំនាំមកនូវភាពរីកចម្រើនធំធេងដល់វិស័យពាណិជ្ជកម្ម ធនាគារ និងផ្តល់ឱកាសរីកចម្រើនដោយប្រយោលដល់វិស័យផ្សេងៗទៀតជាច្រើន។

**ខ)-បញ្ហាបរិស្ថាន ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ**

ការអភិវឌ្ឍវិស័យ **ឲ-ឲ.គ.ព.** នឹងនាំឱ្យមានកំណើននៃការប្រើប្រាស់សម្ភារៈបរិក្ខារបច្ចេកទេសដែលអាចមានផលប៉ះពាល់ដោយផ្ទាល់និងដោយប្រយោលដល់បរិស្ថានតាមរយៈការប្រើប្រាស់ថាមពលអគ្គិសនី។ នៅឆ្នាំ២០០៦ សម្ភារៈបរិក្ខារបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានដែលប្រើប្រាស់បានបញ្ចេញឧស្ម័នពុលប្រមាណ២% ទៅ២,៥% នៃបរិមាណឧស្ម័នពុលទាំងអស់។ ប៉ុន្តែ ផ្ទុយទៅវិញ បច្ចេកវិទ្យានេះក៏អាចជួយការពារបរិស្ថាន តាមរយៈការប្រើប្រាស់វាជាជំនួយដល់ផ្នែកដទៃទៀត ដូចជាការសម្រួលចរាចរណ៍ដើម្បីកាត់បន្ថយការបញ្ចេញឧស្ម័នពុលពីយានយន្ត ការគ្រប់គ្រងការប្រើប្រាស់ថាមពលអគ្គិសនី និងការកាត់បន្ថយក្រដាសស្នាមជាដើម។ល។ **ឲ-ឲ.គ.ព.** ក៏អាចជាឧបករណ៍ ដ៏មានប្រសិទ្ធភាពសម្រាប់ជួយទប់ស្កាត់គ្រោះថ្នាក់ តាមរយៈការផ្តល់ដំណឹងជាមុននិងសង្គ្រោះនៅពេលមានគ្រោះមហន្តរាយ និងគ្រោះធម្មជាតិកើតឡើងផងដែរ។

ក្រៅពីនេះ គ្រោះធម្មជាតិដូចជាខ្យល់កន្ត្រាក់ ព្យុះភ្លៀង ទឹកជំនន់ រន្ទះជាដើម អាចប៉ះពាល់ដល់ឧបករណ៍បរិក្ខារបច្ចេកវិទ្យា និងអាចបង្កការរាំងស្ទះដល់ការផ្តល់សេវា **ឲ-ឲ.គ.ព.**។ ***ដូចនេះដើម្បីធានានិរន្តរភាពនៃការផ្តល់សេវា កាត់បន្ថយហានិភ័យពីគ្រោះធម្មជាតិ ទាំងចំពោះមនុស្ស និងឧបករណ៍បរិក្ខាបច្ចេកវិទ្យា ក៏ដូចជាដើម្បីចូលរួមទទួលខុសត្រូវក្នុងបរិស្ថានជាសកល រាជរដ្ឋាភិបាលនឹងគិតគូរពីការដាក់បញ្ចូលបញ្ហាបរិស្ថាន ការប្រែប្រួលអាកាសធាតុនិងការគ្រប់គ្រងគ្រោះមហន្តរាយទៅក្នុងការអភិវឌ្ឍវិស័យ ឲ.គ.ព.។***

៣.)- **ចក្ខុវិស័យ**

នៅឆ្នាំ២០២០ កម្ពុជានឹងក្លាយជាសង្គមប្រកបដោយសន្តិភាពនិងកម្មញាភាពលើវិស័យ **ទ-ប.គ.ព.** ដើម្បីជាប្រយោជន៍ដល់ប្រជាជនគ្រប់រូបនិងការឈានឡើងរបស់កម្ពុជាទៅកាន់ដំណាក់កាលថ្មីនៃការអភិវឌ្ឍ ពិសេសការធានាឧត្តមភាពប្រកួតប្រជែងរបស់កម្ពុជានៅក្នុងសេដ្ឋកិច្ចពុទ្ធិនាពេលអនាគត។

៤.)- **គោលបំណងនិងគោលដៅ**

គោលនយោបាយអភិវឌ្ឍន៍វិស័យ **ទ-ប.គ.ព.** មានគោលបំណងផ្តល់នូវចក្ខុវិស័យ ក្របខ័ណ្ឌគោល-នយោបាយ ក្របខ័ណ្ឌសម្របសម្រួលក្នុងការអនុវត្ត និងការរៀបចំយន្តការស្ថាប័ន សម្រាប់ជំរុញការអភិវឌ្ឍវិស័យ **ទ-ប.គ.ព.** នៅកម្ពុជា។ គោលនយោបាយនេះមានកម្មវត្ថុសំខាន់ គឺការដោះស្រាយបញ្ហាប្រឈមជារចនាសម្ព័ន្ធ និងការធ្វើឱ្យកាន់តែប្រសើរឡើងនូវបរិយាកាសធុរកិច្ច និងការវិនិយោគលើវិស័យ **ទ-ប.គ.ព.** ប្រកបដោយបរិយាប័ន្ន ចីរភាព និងប្រសិទ្ធភាព ទាំងផ្នែករូបវន្ត និងផ្នែកទន់ ឱ្យសមស្របតាមសក្តានុពល ឧត្តមភាពប្រកួតប្រជែង និងសភាព-ការណ៍វិវត្តន៍ឥតឈប់ឈរនៃបច្ចេកវិទ្យា។ គោលនយោបាយនេះ ក៏មានគោលបំណងដាក់ចេញនូវវិធានការប្រទាក់ក្រឡាគ្នានិងអន្តរាគមន៍ជាក់លាក់តាមតម្រូវការជាក់ស្តែងនិងមានវិសាលភាពគ្របដណ្តប់សម្រាប់រហូតដល់ឆ្នាំ២០២០។

ដើម្បីសម្រេចចក្ខុវិស័យនិងគោលបំណងខាងលើ រាជរដ្ឋាភិបាលសម្រេចយកគោលដៅចំនួនបី៖ ១)-ការពង្រឹងនិងពង្រីកការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធ **ទ-ប.គ.ព.** ២)-ការជំរុញការអភិវឌ្ឍធនធានមនុស្ស និង៣)-ការអភិវឌ្ឍឧស្សាហកម្ម **ប.គ.ព.** ឱ្យមានភាពសម្បូរបែបនិងការជំរុញការប្រើប្រាស់ **ប.គ.ព.**។

**១-ការពង្រឹងនិងពង្រីកការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធ និងការប្រើប្រាស់សេវាទូរគមនាគមន៍ តាមរយៈការពង្រីកវិសាលភាពអ៊ិនធឺណិតល្បឿនលឿនគ្របដណ្តប់លើទីប្រជុំជន និងតាមទីជនបទ ព្រមទាំងបង្កើនអត្រាប្រើប្រាស់ទូរស័ព្ទដៃអ៊ិនធឺណិតនិងការប្រើប្រាស់កុំព្យូទ័រ ដូចមានកំណត់ក្នុងតារាងខាងក្រោម៖**

*ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនិងការប្រើប្រាស់សេវាទូរគមនាគមន៍*

| | **អត្រាគោលដៅឆ្នាំ២០២០** |
|---|---|
| វិសាលភាពអ៊ិនធឺណិតល្បឿនលឿនគ្របដណ្តប់លើទីប្រជុំជន | ១០០% |
| វិសាលភាពអ៊ិនធឺណិតល្បឿនលឿនគ្របដណ្តប់លើទីជនបទ | ៧០% |
| អត្រានៃការប្រើប្រាស់សេវាទូរស័ព្ទចល័ត | ១០០% |
| អត្រានៃការប្រើប្រាស់សេវាអ៊ិនធឺណិត | ៨០% |
| អត្រានៃការប្រើប្រាស់សេវាអ៊ិនធឺណិតល្បឿនលឿន | ៧០% |
| អត្រាគ្រួសារដែលប្រើប្រាស់សេវាអ៊ិនធឺណិត | ៣០% |
| អត្រាគ្រួសារដែលមានកុំព្យូទ័រប្រើប្រាស់ | ៣០% |
| អត្រានៃការតភ្ជាប់អ៊ិនធឺណិតនៃវត្ថុ (Internet of Things) | ១០% |

២. ការជំរុញការអភិវឌ្ឍធនធានមនុស្ស តាមរយៈការបង្កើនអត្រានៃមន្ត្រីរាជការថ្នាក់កណ្ដាល មន្ត្រីរាជការថ្នាក់មូលដ្ឋានឱ្យចេះប្រើប្រាស់សូហ្វវែរកម្មវិធីមូលដ្ឋាន អត្រាសិស្សានុសិស្សដែលបញ្ចប់ការសិក្សាថ្នាក់ទុតិយភូមិទាំងអស់មានបំណិនវិជ្ជាជីវៈ ប.ស.ព. និងបង្កើនអត្រាធនធានមនុស្សដែលមានជំនាញវិជ្ជាជីវៈ ប.ស.ព.។

*ការជំរុញការអភិវឌ្ឍធនធានមនុស្ស*

| | អត្រាគោលដៅឆ្នាំ២០២០ |
|---|---|
| អត្រានៃមន្ត្រីរាជការថ្នាក់កណ្ដាលដែលចេះប្រើប្រាស់សូហ្វវែរកម្មវិធីមូលដ្ឋាន | ៩៥% |
| អត្រាមន្ត្រីរាជការថ្នាក់មូលដ្ឋានដែលចេះប្រើប្រាស់សូហ្វវែរកម្មវិធីមូលដ្ឋាន | ៧៥% |
| អត្រាសិស្សដែលបញ្ចប់ការសិក្សាទុតិយភូមិទទួលបានការបណ្ដុះ បណ្ដាលបំណិនវិជ្ជាជីវៈ ផ្នែក **ប.ស.ព.** | ១០០% |
| អត្រានៃធនធានមនុស្សដែលមានជំនាញវិជ្ជាជីវៈ **ប.ស.ព.** ភ្ជាប់ជាមួយជំនាញដទៃទៀត | ១៥% |
| អត្រានៃអ្នកបច្ចេកទេសក្នុងវិស័យ **ប.ស.ព.** សម្រាប់ការស្រាវជ្រាវ និងការអភិវឌ្ឍ | ៣០ នាក់ក្នុង ១ លាននាក់ |
| អត្រានៃអ្នកស្រាវជ្រាវក្នុងវិស័យ **ប.ស.ព.** | ១០ នាក់ក្នុង ១ លាននាក់ |

៣-ការអភិវឌ្ឍឧស្សាហកម្ម ប.ស.ព. ឱ្យមានភាពសម្បូរបែបដោយពង្រឹងយន្តការគ្រប់គ្រង ការរៀបចំណាត់ថ្នាក់ និងការចុះបញ្ជីនៃក្រុមហ៊ុនផលិត និងផ្ដល់សេវាកម្ម ប.ស.ព. និងជំរុញការប្រើប្រាស់ ប.ស.ព. តាមរយៈការជំរុញការប្រើប្រាស់សារអេឡិចត្រូនិក និងគេហទំព័រតាមស្ថាប័នរដ្ឋាភិបាល ។

*ការជំរុញការអភិវឌ្ឍវិស័យឧស្សាហកម្ម ឧ-ប.ស.ព. និងការជំរុញការប្រើប្រាស់*

| | អត្រាគោលដៅឆ្នាំ២០២០ |
|---|---|
| អត្រាក្រុមហ៊ុន **ឧ-ប.ស.ព.** បានចុះបញ្ជីជាផ្លូវការ | ស្របតាមអត្រានៅឆ្នាំ២០២០ដែលត្រូវបានកំណត់នៅក្នុងគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម |
| អត្រានៃការប្រើប្រាស់សារអេឡិចត្រូនិករបស់ក្រសួង-ស្ថាប័នរាជរដ្ឋាភិបាលថ្នាក់ជាតិនិងក្រោមជាតិ | ១០០% |
| អត្រានៃការប្រើប្រាស់គេហទំព័រតាមស្ថាប័នរដ្ឋ | ១០០% |

## ៥.)- ក្របខ័ណ្ឌយុទ្ធសាស្ត្រ

ដើម្បីសម្រេចចក្ខុវិស័យ គោលបំណង និងគោលដៅខាងលើ រាជរដ្ឋាភិបាលដាក់ចេញនូវយុទ្ធសាស្ត្រចម្បង ចំនួនបី៖

១. ពង្រឹងមូលដ្ឋាននៃការអភិវឌ្ឍវិស័យ **ទ-ប.គ.ព.** ។

២. ពង្រឹងសន្តិសុខនិងជំរុញការអភិវឌ្ឍឧស្សាហកម្ម **ទ-ប.គ.ព.**។

៣. ជំរុញការប្រើប្រាស់ **ប.គ.ព.** ។

## ៦.)- វិធានការគោលនយោបាយនិងផែនការសកម្មភាព

នៅក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្រខាងលើនេះ រាជរដ្ឋាភិបាលដាក់ចេញនិងជំរុញអនុវត្តវិធានការគោលនយោបាយ សំខាន់ៗ ដូចខាងក្រោម៖

### ៦.១)-ការពង្រឹងមូលដ្ឋាននៃការអភិវឌ្ឍវិស័យទូរគមនាគមន៍-បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន (ទ-ប.គ.ព.)

**ក. ក្របខ័ណ្ឌគោលនយោបាយនិងគតិយុត្ត**

- ជំរុញការរៀបចំនិងការអនុម័តគោលនយោបាយអ៊ិនធឺណិតល្បឿនលឿន (broadband policy) គោលនយោបាយវិទ្យុគមនាគមន៍ គោលនយោបាយកាតព្វកិច្ចសេវាសកល និងគោលនយោបាយ ឬ ផែនការយុទ្ធសាស្ត្រគាំទ្រផ្សេងៗពាក់ព័ន្ធនឹងវិស័យ **ទ-ប.គ.ព.** ដោយយកចិត្តទុកដាក់លើគ្រប់ទិដ្ឋភាពសេដ្ឋកិច្ចនិងសង្គម និងសុខដុមនីយកម្មក្នុងតំបន់និងពិភពលោក។
- ជំរុញការរៀបចំនិងការអនុម័ត ច្បាប់ស្តីពីពាណិជ្ជកម្មអេឡិកត្រូនិក អនុក្រឹត្យស្តីពីវិទ្យុគមនាគមន៍ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតពាក់ព័ន្ធនឹងវិស័យ **ទ-ប.គ.ព.** ជាអាទិ៍ រដ្ឋាភិបាលអេឡិកត្រូនិក និងហត្ថលេខាឌីជីថល ដើម្បីធានាការប្រកួតប្រជែងស្មោះត្រង់និងស្របច្បាប់ ការប្រើប្រាស់ធនធានទូរគមនាគមន៍កម្រឱ្យមានប្រសិទ្ធភាព និងជំរុញការអភិវឌ្ឍពាណិជ្ជកម្មតាមប្រព័ន្ធអេឡិកត្រូនិក និងកសាងទំនុកចិត្តលើប្រតិបត្តិការហិរញ្ញវត្ថុតាមប្រព័ន្ធអេឡិកត្រូនិក។
- ជំរុញកិច្ចសហការរៀបចំនិងអនុម័តច្បាប់ស្តីពីការបង្ក្រាបឧក្រិដ្ឋកម្មតាមប្រព័ន្ធ **ប.គ.ព.** ។
- ជំរុញការរៀបចំនិងការអនុម័តលិខិតបទដ្ឋានគតិយុត្តស្តីពីការការពារសិទ្ធិកុមារនិងស្ត្រី លើការប្រើប្រាស់ប្រព័ន្ធ **ប.គ.ព.** និងការការពារព័ត៌មានឯកជនតាមប្រព័ន្ធ **ប.គ.ព.**។
- ជំរុញការធ្វើនិយ័តកម្មលើវិស័យ **ទ-ប.គ.ព.**។
- បង្កើនការយកចិត្តទុកដាក់លើការគ្រប់គ្រងធនធានកម្រ ជាពិសេសវិសាលគមន៍វិទ្យុគមនាគមន៍។

**ខ-ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ទ-ប.គ.ព.**

- ជំរុញការវិនិយោគលើការតភ្ជាប់តាមខ្សែកាប្លិ៍អុបទិកក្រោមបាតសមុទ្រនិងតាមប្រព័ន្ធផ្កាយរណប។
- ជំរុញការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធអ៊ិនធឺណិតល្បឿនលឿនឱ្យបានទូលំទូលាយលើផ្ទៃប្រទេស ដើម្បីផ្តល់ភាពងាយស្រួលក្នុងការប្រើប្រាស់និងមានតម្លៃសមរម្យ (accessibility affordability and

availability) ជាពិសេសនៅតាមវិទ្យាល័យរដ្ឋ តំបន់ឧស្សាហកម្ម តំបន់ទេសចរណ៍ និងតំបន់ដែលមានសក្តានុពលសេដ្ឋកិច្ច តាមរយៈការរៀបចំគោលនយោបាយលើកទឹកចិត្តដល់ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធទាំងនេះនិងការអនុវត្តកម្មវិធីកាតព្វកិច្ចសេវាសកល។

- លើកទឹកចិត្តការប្រើប្រាស់ឱ្យអស់លទ្ធភាពនូវហេដ្ឋារចនាសម្ព័ន្ធឆ្អឹងខ្នងនិងហេដ្ឋារចនាសម្ព័ន្ធរួម។
- ជំរុញកិច្ចសហការរវាងក្រសួង-ស្ថាប័នពាក់ព័ន្ធក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគាំទ្រ ដើម្បីពន្លឿនឌីជីថលូបនីយកម្មនៃប្រព័ន្ធសោតទស្សន៍ និងការផ្តល់សេវារួមសម្រាប់វិស័យ **ឧ-ប.គ.ព.** និងសោត-ទស្សន៍។
- ជំរុញកិច្ចសហការរវាងក្រសួង-ស្ថាប័នពាក់ព័ន្ធក្នុងការរៀបចំប្លង់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងបណ្តាញរួមលើវិស័យទូរគមនាគមន៍ដោយត្រូវបន្សីជាមួយនឹងប្លង់ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ ការផ្គត់ផ្គង់ថាមពល ការបំភ្លឺសាធារណៈ ការផ្គត់ផ្គង់ទឹកស្អាត ការបង្ហូរកាកសំណល់រឹងនិងរាវ និងប្លង់ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀត។
- ស្ថាបនានិងពង្រីកបណ្តាញតភ្ជាប់រវាងក្រុមហ៊ុនផ្តល់សេវាអ៊ិនធឺណេត ទាំងក្នុងស្រុកនិងច្រកទ្វារអន្តរជាតិ ជាពិសេសបណ្តាញតភ្ជាប់អ៊ិនធឺណិតរវាងកម្ពុជានិងអាស៊ាន (Internet Exchange Point)។
- ធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធព័ត៌មានជាតិ ដោយពិនិត្យ រៀបចំ និងថែទាំបណ្តាញដែលមានស្រាប់ ព្រមទាំងកៀរគរធនធានសម្រាប់ពង្រីកបណ្តាញបន្ថែម។
- ពង្រឹងសមត្ថភាពលើការគ្រប់គ្រងធនធានអាសយដ្ឋានអេឡិកត្រូនិកនិងរៀបចំឱ្យមានក្របខ័ណ្ឌបច្ចេកទេសទាក់ទងនឹងការប្រើប្រាស់អាសយដ្ឋាន IPv6 នៅកម្ពុជា។
- បង្កើតមជ្ឈមណ្ឌលគ្រប់គ្រងទិន្នន័យរួមសម្រាប់រាជរដ្ឋាភិបាលដោយប្រើប្រាស់បច្ចេកវិទ្យាពពក។
- ធ្វើបច្ចុប្បន្នភាពប្លង់លេខទូរគមនាគមន៍និងក្បាលលេខទូរគមនាគមន៍ជាតិ។
- សិក្សាពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុលើហេដ្ឋារចនាសម្ព័ន្ធ **ឧ-ប.គ.ព.**។
- រៀបចំនិងបង្កើតក្របខ័ណ្ឌបច្ចេកទេសដើម្បីបន្សាំនឹងការប្រែប្រួលអាកាសធាតុរបស់ហេដ្ឋារចនាសម្ព័ន្ធ **ឧ-ប.គ.ព.** ។

## គ-ការកាត់បន្ថយគម្លាតឌីជីថល

- រៀបចំយន្តការសម្រាប់អនុវត្តកម្មវិធីកាតព្វកិច្ចសេវាសកលក្នុងវិស័យ **ឧ-ប.គ.ព.**។
- ជំរុញនិងលើកទឹកចិត្តការប្រើប្រាស់ភាសាជាតិក្នុងសូហ្វវែរកម្មវិធី មាតិកាព័ត៌មាន និងឯកសារបច្ចេកទេសនានា ដើម្បីបង្កភាពងាយស្រួលដល់ប្រជាពលរដ្ឋក្នុងការប្រើប្រាស់និងស្វែងយល់អំពី **ប.គ.ព.**។
- រៀបរៀងវចនានុក្រមបច្ចេកស័ព្ទក្នុងវិស័យ **ឧ-ប.គ.ព.**។
- បញ្ជ្រាបការយល់ដឹងនិងជំរុញការប្រើប្រាស់ **ប.គ.ព.** សម្រាប់ការអភិវឌ្ឍសហគមន៍នៅតាមជនបទ។
- ជំរុញការផលិតនិងការប្រើប្រាស់បច្ចេកវិទ្យាជំនួយសម្រាប់ជនពិការ ។

- លើកទឹកចិត្តស្ត្រីឱ្យចូលរួមក្នុងការអភិវឌ្ឍវិស័យ **ឌ-ប.គ.ព.** តាមរយៈការផ្តល់ឱកាសដល់ស្ត្រីទទួលបានការបណ្តុះបណ្តាលជំនាញនិងមានឱកាសការងារ ឬបំពេញការងារពីចម្ងាយប្រកបដោយប្រសិទ្ធភាព និងគ្មានការរើសអើង។
- លើកទឹកចិត្តឱ្យមានការប្រើប្រាស់ **ប.គ.ព.** សម្រាប់បញ្ជ្រាបការយល់ដឹងអំពីយេនឌ័រ។

**ឃ-ការលើកកម្ពស់កម្រិតអក្ខរកម្ម ការអភិវឌ្ឍធនធានមនុស្សជំនាញ និងការស្រាវជ្រាវ និងអភិវឌ្ឍន៍លើវិស័យ ឌ-ប.គ.ព.**

- រៀបចំក្របខ័ណ្ឌអក្ខរកម្ម **ប.គ.ព.** ដើម្បីលើកកម្ពស់សមត្ថភាពប្រជាជនក្នុងការប្រើប្រាស់ **ប.គ.ព.** សម្រាប់ការទទួលបានការគ្រប់គ្រង ការសិក្សា ការវិភាគ និងការបង្កើតព័ត៌មាន។
- បញ្ជ្រាបការយល់ដឹងអំពីសារប្រយោជន៍នៃការប្រើប្រាស់សេវា **ឌ-ប.គ.ព.** ទៅដល់គ្រប់តួអង្គ ជាពិសេស យុវជន និងស្ត្រី និងគ្រប់ទីកន្លែង តាមរយៈសិក្ខាសាលា ការបោះពុម្ពផ្សាយ និងការផ្សព្វផ្សាយទៅតាមមធ្យោបាយផ្សេងៗទៀត ។
- រៀបចំផែនការលើកកម្ពស់កម្រិតអក្ខរកម្ម **ឌ-ប.គ.ព.** មូលដ្ឋាន ដល់មន្ត្រីរាជការក្នុងស្ថាប័នសាធារណៈ តាមរយៈការដាក់ចេញនូវកម្មវិធីបណ្តុះបណ្តាលទៀងទាត់និងសម្បូរបែបតាមតម្រូវការជាក់ស្តែង។
- បង្កើតយន្តការពិនិត្យនិងវាយតម្លៃជារៀងរាល់ឆ្នាំអំពីកម្រិតយល់ដឹង និងជំនាញប្រើប្រាស់ **ឌ-ប.គ.ព.** របស់មន្ត្រីរាជការនិងនិស្សិត។
- ជំរុញកិច្ចសហការរវាងក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីរៀបចំកម្មវិធីសិក្សាផ្នែក **ឌ-ប.គ.ព.** ឱ្យមានភាពសម្បូរបែបនិងទាន់សម័យ សម្រាប់គ្រឹះស្ថានឧត្តមសិក្សា វិទ្យាល័យ អនុវិទ្យាល័យ និងស្ថាប័នបណ្តុះបណ្តាលជំនាញដទៃទៀត។
- ជំរុញកិច្ចសហការរវាងក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីពង្រឹងសមត្ថភាពគ្រូបង្រៀនជំនាញខាងផ្នែក **ឌ.-ប.គ.ព.** និងអន្តរជំនាញ និងសម្រាប់គ្រឹះស្ថានឧត្តមសិក្សា វិទ្យាល័យ អនុវិទ្យាល័យ និងស្ថាប័នបណ្តុះបណ្តាលជំនាញដទៃទៀត។
- រៀបចំប្រព័ន្ធទិន្នន័យគ្រប់គ្រងធនធានមនុស្សជំនាញ **ឌ-ប.គ.ព.** ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការទីផ្សារការងារនិងចូលរួមសហការរៀបចំផែនការអភិវឌ្ឍធនធានមនុស្សនាពេលអនាគត។
- ជំរុញកិច្ចសហការរវាងក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីរៀបចំគោលនយោបាយលើកកម្ពស់ជំនាញវិជ្ជាជីវៈ និងគ្រូបង្គោល ព្រមទាំងអ្នកស្រាវជ្រាវក្នុងវិស័យ **ឌ-ប.គ.ព.**។
- ជំរុញការបង្កើតមជ្ឈមណ្ឌលប្រលងយកវិញ្ញាបនបត្រឯកទេសខាងផ្នែក **ឌ-ប.គ.ព.** តាមស្តង់ដាអន្តរជាតិ ។
- រៀបចំផែនការមេសម្រាប់ជំរុញការស្រាវជ្រាវនិងការអភិវឌ្ឍលើវិស័យ **ឌ-ប.គ.ព.**។
- ជំរុញការស្រាវជ្រាវនិងអភិវឌ្ឍបច្ចេកវិទ្យាថ្មីៗ និងនវានុវត្តន៍ក្នុងវិស័យ **ឌ-ប.គ.ព.** ដោយលើកទឹកចិត្តឱ្យមានកិច្ចសហការរវាងសាកលវិទ្យាល័យវិស័យសាធារណៈនិងវិស័យឯកជន។

- រៀបចំយន្តការសម្រាប់គ្រប់គ្រងផែនការកសាងសមត្ថភាព និងការស្រាវជ្រាវ និងអភិវឌ្ឍក្នុងវិស័យ **ឌ-ប.គ.ព.**។

## ៦.២)-ការពង្រឹងសន្តិសុខនិងការអភិវឌ្ឍឧស្សាហកម្មទូរគមនាគមន៍-បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន (ឌ-ប.គ.ព.)

### ក-ការពង្រឹងសន្តិសុខ ឌ-ប.គ.ព.

- បញ្ជ្រាបការយល់ដឹងខាងផ្នែកសន្តិសុខ **ឌ-ប.គ.ព.** ទៅតាមកម្រិតដល់តួអង្គពាក់ព័ន្ធ។
- រៀបចំនិងជំរុញការអនុវត្តសេចក្តីណែនាំនិងវិធានបច្ចេកទេសផ្សេងៗស្តីពីសន្តិសុខ **ឌ-ប.គ.ព.** ទៅដល់តួអង្គពាក់ព័ន្ធ។
- រៀបចំក្របខ័ណ្ឌបច្ចេកទេសថ្នាក់ជាតិស្តីពីសន្តិសុខ **ឌ-ប.គ.ព.**។
- ពង្រឹងសមត្ថភាពក្រុមការងារជាតិឆ្លើយតបទៅនឹងបញ្ហាបន្ទាន់នៃកុំព្យូទ័រ ដើម្បីការពារ និងទប់ស្កាត់ប្រកបដោយប្រសិទ្ធភាពទៅនឹងការវាយប្រហារនានាមកលើប្រព័ន្ធព័ត៌មានក្នុងស្រុក។
- បង្កើនការយកចិត្តទុកដាក់អំពីស្ថិរភាពនិងសុវត្ថិភាពគេហទំព័រស្ថាប័នសាធារណៈគ្រប់លំដាប់ថ្នាក់ដោយដាក់ចេញវិធានការទប់ទល់នឹងការវាយប្រហារដែលបង្កឱ្យខូចខាតព័ត៌មាន និងវិធីសាស្ត្រធានានិរន្តរភាពនៃដំណើរការគេហទំព័រ។
- បង្កើតយន្តការភាពជាដៃគូរវាងស្ថាប័នរដ្ឋ សកលវិទ្យាល័យ និងឯកជន ដាក់ចេញផែនការសកម្មភាពជាក់ស្តែង ក្នុងការឆ្លើយតបចំពោះការគំរាមកំហែងដល់សន្តិសុខ **ឌ-ប.គ.ព.** និងយកចិត្តទុកដាក់បណ្តុះបណ្តាលមន្ត្រីជំនាញនិងលើកកម្ពស់ជំនាញពាក់ព័ន្ធនឹងប្រព័ន្ធសន្តិសុខ **ឌ-ប.គ.ព.**។
- រៀបចំបទដ្ឋានបច្ចេកទេសសម្រាប់ការងារកោសល្យវិច័យឌីជីថល និងបង្កើតមជ្ឈមណ្ឌលកោសល្យ-វិច័យឌីជីថលថ្នាក់ជាតិសម្រាប់ធ្វើកោសល្យវិច័យនិងបញ្ជាក់ភស្តុតាងឌីជីថល។
- បង្កើតមជ្ឈមណ្ឌលជាតិគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធគន្លឹះសាធារណៈ (Public Key Infrastructure) សម្រាប់ផ្តល់អាជ្ញាបណ្ណ ដល់ក្រុមហ៊ុនផ្តល់សេវាបញ្ជាក់ហត្ថលេខាឌីជីថល។
- កំណត់អត្តសញ្ញាណកម្មនៃហេដ្ឋារចនាសម្ព័ន្ធព័ត៌មានសំខាន់ៗ (Critical Information infrastructure) និងបង្កើតយន្តការការពារហេដ្ឋារចនាសម្ព័ន្ធទាំងនោះ។
- បង្កើនកិច្ចសហការប្រយុទ្ធប្រឆាំងនឹងការវាយប្រហារមកលើហេដ្ឋារចនាសម្ព័ន្ធព័ត៌មាន តាមរយៈការចែករំលែកនិងផ្លាស់ប្តូរបទពិសោធន៍ និងព័ត៌មានជាមួយបណ្តាប្រទេសក្នុងតំបន់និងលើសកលលោក។
- ជំរុញកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នជាតិនិងអន្តរជាតិ បង្កើតទំនាក់ទំនង ដើម្បីតាមដានបង្ការទប់ស្កាត់ និងការពារសន្តិសុខ **ឌ-ប.គ.ព.**។

### ខ-ការអភិវឌ្ឍឧស្សាហកម្ម ឌ-ប.គ.ព.

- ជំរុញការពង្រឹងគុណភាពនិងពិពិធកម្មសេវា **ឌ-ប.គ.ព.** ឱ្យកាន់តែប្រសើរ ទាន់សម័យ និងសម្បូរបែប។

- លើកទឹកចិត្តការវិនិយោគលើវិស័យ **ប.គ.ព.** មានជាអាទិ៍ ការអភិវឌ្ឍសូហ្វវែរកម្មវិធី មាតិកាព័ត៌មាន ការផលិតឧបករណ៍គ្រឿងសម្ភារៈបរិក្ខារ **ឌ-ប.គ.ព.** និងការផ្តល់សេវាផ្សេងៗ។
- រៀបចំគោលនយោបាយលើកទឹកចិត្តនានា រួមទាំងការសម្រួលលើការចុះបញ្ជីពាណិជ្ជកម្ម និងការផ្តល់អាជ្ញាបណ្ណ ព្រមទាំងធានានូវបរិស្ថានប្រកួតប្រជែងដោយស្មើភាព តម្លាភាព និងបើកចំហ។
- រៀបចំផែនការយុទ្ធសាស្ត្រសម្រាប់អភិវឌ្ឍឧស្សាហកម្ម **ប.គ.ព.** ក្នុងរយៈ ពេលខ្លី មធ្យម និងវែង។
- រៀបចំប្រព័ន្ធទិន្នន័យ និងស្ថិតិលើវិស័យ **ឌ-ប.គ.ព.** តាមរយៈការបង្កើតយន្តការប្រមូល សិក្សា វិភាគ រក្សាទុក និងផ្សព្វផ្សាយ។
- បង្កើតស្តង់ដាជាតិសម្រាប់វិស័យ **ឌ-ប.គ.ព.។**
- ជំរុញការរៀបចំចំណាត់ថ្នាក់ប្រតិបត្តិករទូរគមនាគមន៍ ដោយធ្វើការបែងចែកប្រតិបត្តិករហេដ្ឋារចនាសម្ព័ន្ធនិងបណ្តាញពីប្រតិបត្តិករសេវាទូរគមនាគមន៍ ដើម្បីជំរុញនិងទាក់ទាញការវិនិយោគ ការបង្កើតសេវាថ្មីៗ និងការបង្កើនភាពប្រកួតប្រជែង។
- ជំរុញការផ្តល់អាជ្ញាបណ្ណ វិញ្ញាបនបត្រ ឬលិខិតអនុញ្ញាតសម្រាប់ការនាំចូល ការផលិត ការផ្គុំដំឡើង និងចែកចាយសូហ្វវែរ គ្រឿងសម្ភារៈបរិក្ខារ និងការផ្តល់សេវាបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានផ្សេងទៀត។
- ជំរុញការវិនិយោគក្នុងការបង្កើតសួនឧស្សាហកម្ម **ប.គ.ព.**។
- បង្កើតយន្តការសហប្រតិបត្តិការរវាងវិស័យសាធារណៈ និងឯកជន អង្គការមិនមែនរដ្ឋាភិបាល និងអន្តរជាតិ ព្រមទាំងជាមួយដៃគូអភិវឌ្ឍនានា ទាំងកម្រិតតំបន់ និងពិភពលោក ដើម្បីចែករំលែកចំណេះដឹង ការផ្ទេរបច្ចេកវិទ្យា បទពិសោធន៍ ឧត្តមានុវត្ត និងការកសាងសមត្ថភាព។
- បន្តរៀបចំព្រឹត្តិការណ៍នានា ដើម្បីបង្ហាញអំពីការវិវត្តនៃបច្ចេកវិទ្យាចុងក្រោយ និងអត្ថប្រយោជន៍នៃការប្រើប្រាស់បច្ចេកវិទ្យាក្នុងវិស័យឧស្សាហកម្ម។
- បន្តរៀបចំការប្រកួតប្រជែងលើឧស្សាហកម្មបច្ចេកវិទ្យាឈានមុខនៅកម្ពុជា ដើម្បីលើកទឹកចិត្តដល់ការស្រាវជ្រាវនិងអភិវឌ្ឍ និងនវានុវត្តន៍។
- ជំរុញនិងលើកទឹកចិត្តក្រុមហ៊ុនក្នុងស្រុក ចូលរួមលទ្ធកម្មលើគម្រោងរបស់រាជរដ្ឋាភិបាលពាក់ព័ន្ធនឹងវិស័យ **ឌ-ប.គ.ព.**។

### ៦.៣)-ការជំរុញការប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន (ប.គ.ព.)

***ក-ការអភិវឌ្ឍនិងប្រើប្រាស់សូហ្វវែរកម្មវិធីក្នុងក្របខ័ណ្ឌរដ្ឋាភិបាលអេឡិកត្រូនិក***

- រៀបចំក្របខ័ណ្ឌនិងយន្តការរដ្ឋាភិបាលអេឡិកត្រូនិករួមមួយ ដើម្បីបំពេញការងារប្រកបដោយប្រសិទ្ធភាព សន្សំសំចៃពេលវេលានិងថវិកា។
- សិក្សាស្រាវជ្រាវ និងកំណត់អាទិភាពសូហ្វវែរកម្មវិធីចាំបាច់ ដើម្បីប្រើប្រាស់ក្នុងក្រសួង-ស្ថាប័នសាធារណៈ និងរៀបចំផែនការពង្រីកសេវារដ្ឋាភិបាលអេឡិកត្រូនិកសម្រាប់រយៈពេលខ្លី មធ្យម និងវែង។

- បង្កើតក្រុមការងារមន្ត្រីបង្គោលទទួលបន្ទុកផ្នែកបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ដោយមានការចូលរួមពីមន្ត្រីបង្គោលនៅតាមក្រសួង-ស្ថាប័នសាធារណៈពាក់ព័ន្ធ។
- ជំរុញការអភិវឌ្ឍ និងការប្រើប្រាស់សូហ្វវែរកម្មវិធី មានជាអាទិ៍ កម្មវិធីគ្រប់គ្រងមន្ត្រីរាជការ គ្រប់គ្រងឯកសាររដ្ឋាភិបាល គ្រប់គ្រងហិរញ្ញវត្ថុ គ្រប់គ្រងសេវាសាធារណៈ និងកម្មវិធីសម្រួលពាណិជ្ជកម្ម ព្រមទាំងសូហ្វវែរកម្មវិធីផ្សេងៗទៀត ដើម្បីផ្តល់សេវាជូនប្រជាជន។
- ជំរុញកិច្ចសហការរវាងក្រសួង-ស្ថាប័នពាក់ព័ន្ធដើម្បីរៀបចំប្រព័ន្ធទិន្នន័យរួមថ្នាក់ជាតិ និងប្រព័ន្ធបញ្ចរតែមួយជាតិ សម្រាប់សមាហរណកម្មសេដ្ឋកិច្ចអាស៊ាន និងសូហ្វវែរកម្មវិធីចាំបាច់ដទៃទៀត។

***ខ-ការជំរុញពាណិជ្ជកម្មអេឡិកត្រូនិក***

- បញ្ជ្រាបការយល់ដឹងអំពីផលប្រយោជន៍ និងហានិភ័យនៃការប្រើប្រាស់ពាណិជ្ជកម្មអេឡិកត្រូនិកដល់ប្រជាជន។
- ជំរុញការអភិវឌ្ឍនិងការប្រើប្រាស់ប្រតិបត្តិការទូទាត់ប្រាក់តាមប្រព័ន្ធអេឡិកត្រូនិក ប្រកបដោយទំនុកចិត្តនិងសុវត្ថិភាព។
- លើកកម្ពស់គុណភាពនិងប្រសិទ្ធភាពប្រព័ន្ធឡូជីស្ទិកនៅក្នុងពាណិជ្ជកម្មអេឡិកត្រូនិក។
- ជំរុញកិច្ចសហការរវាងក្រសួង-ស្ថាប័នពាក់ព័ន្ធក្នុងការរៀបចំយន្តការប្រមូលពន្ធ និងអាករផ្សេងៗលើពាណិជ្ជកម្មអេឡិកត្រូនិក។

***គ-ការប្រើប្រាស់ប្រព័ន្ធ ឱ-ម.គ.ព. សម្រាប់ការពារបរិស្ថាន ការសម្របនឹងការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងគ្រោះមហន្តរាយ***

- រៀបចំនិងអនុវត្តផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុក្នុងវិស័យ **ឱ-ម.គ.ព.**។
- ជំរុញកិច្ចសហការរវាងក្រសួង-ស្ថាប័នពាក់ព័ន្ធរៀបចំក្របខ័ណ្ឌបច្ចេកទេសរួម សម្រាប់ការបញ្ជ្រាបការយល់ដឹងអំពីបរិស្ថាននិងការប្រែប្រួលអាកាសធាតុតាមរយៈការប្រើប្រាស់ប្រព័ន្ធ **ឱ-ម.គ.ព.**។
- រៀបចំកម្មវិធីបណ្តុះបណ្តាល និងបញ្ជ្រាបការយល់ដឹងស្តីពីការសម្របទៅនឹងការផ្លាស់ប្តូរអាកាសធាតុក្នុងវិស័យ **ឱ-ម.គ.ព.**។
- ជំរុញកិច្ចសហការរវាងក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីរៀបចំប្រព័ន្ធគ្រប់គ្រងទិន្នន័យរួមសម្រាប់ផ្ទុកទិន្នន័យសំខាន់ៗក្នុងការគ្រប់គ្រងគ្រោះមហន្តរាយ ការការពារបរិស្ថាន និងការប្រែប្រួលអាកាសធាតុ។
- ជំរុញការប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានបៃតង តាមរយៈការលើកទឹកចិត្តការផលិតនិងការនាំចូលសម្ភារៈបរិក្ខារបច្ចេកវិទ្យាទំនើបនិងសន្សំសំចៃថាមពល។
- ជំរុញការប្រើប្រាស់ប្រព័ន្ធ **ឱ-ម.គ.ព.** សម្រាប់គ្រប់គ្រងធនធានធម្មជាតិ កាកសំណល់ និងការប្រើប្រាស់ថាមពល។
- ជំរុញការប្រើប្រាស់ប្រព័ន្ធ **ឱ-ម.គ.ព.** សម្រាប់ត្រៀមខ្លួនឆ្លើយតបទៅនឹងគ្រោះមហន្តរាយ គ្រោះធម្មជាតិ និងការផ្តល់សេវាសង្គ្រោះបន្ទាន់។

## ៧.)- យន្តការដឹកនាំ សម្របសម្រួល និងអនុវត្តគោលនយោបាយ

### ៧.១)-ស្ថាប័នដឹកនាំ សម្របសម្រួល និងការពង្រឹងអង្គភាពជំនាញ

រាជរដ្ឋាភិបាលកម្ពុជាប្រគល់ភារកិច្ចជូនក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ជាក្រសួងមានសមត្ថកិច្ចសម្រាប់ដឹកនាំ និងគ្រប់គ្រងលើវិស័យ **ឌ-ប.គ.ព.** និងមានភារកិច្ចជាស្ថាប័នសម្របសម្រួលអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យ **ឌ-ប.គ.ព.**។ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ត្រូវបង្កើតយន្តការសម្របសម្រួលជាមួយក្រសួង-ស្ថាប័នថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងវិស័យឯកជន ដើម្បីអនុវត្តគោលនយោបាយនេះឱ្យទទួលបានជោគជ័យ។ នៅក្នុងក្របខ័ណ្ឌស្ថាប័នសាធារណៈ រាជរដ្ឋាភិបាលលើកទឹកចិត្តឱ្យមានការបង្កើតអង្គភាពជំនាញនៅតាមក្រសួង-ស្ថាប័ននានា ដើម្បីទទួលខុសត្រូវផ្នែក **ប.គ.ព.** នៅតាមក្រសួង-ស្ថាប័នរបស់ខ្លួន។ អង្គភាពជំនាញត្រូវទំនាក់ទំនង និងសម្របសម្រួលកិច្ចការបច្ចេកទេសជាមួយអង្គភាពជំនាញរបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ដើម្បីធានានូវភាពអាចប្រាស្រ័យទាក់ទងគ្នានៃប្រព័ន្ធ **ឌ-ប.គ.ព.** ប្រកបដោយប្រសិទ្ធភាពនិងស័ក្តិសិទ្ធិភាព។

### ៧.២)-យន្តការពិគ្រោះយោបល់ជាមួយវិស័យឯកជន-ស្ថាប័នស្រាវជ្រាវ

វិស័យឯកជននិងស្ថាប័នស្រាវជ្រាវដើរតួនាទីយ៉ាងសំខាន់ក្នុងការវិនិយោគលើវិស័យ **ឌ-ប.គ.ព.** នៅក្នុងប្រទេសកម្ពុជា។ ហេតុនេះ រាជរដ្ឋាភិបាលកម្ពុជាចាត់ទុកវិស័យឯកជននិងស្ថាប័នស្រាវជ្រាវជាដៃគូចូលរួមកំណត់ទិសដៅអភិវឌ្ឍវិស័យនេះឱ្យបានជោគជ័យ តាមរយៈការដាក់ចេញនូវយន្តការពិគ្រោះយោបល់។ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ដឹកនាំនិងសម្របសម្រួលការពិគ្រោះយោបល់ ដើម្បីស្នើឱ្យមានការកែសម្រួលក្របខ័ណ្ឌគោល-នយោបាយនិងគតិយុត្ត ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពនានា តាមរយៈការស្វែងរកធាតុចូល សិក្សា វិភាគ និងរកដំណោះស្រាយលើបញ្ហាពាក់ព័ន្ធនឹងវិស័យនេះ សំដៅជំរុញការអភិវឌ្ឍវិស័យនេះ ប្រកបដោយបរិយាប័ន្ន ចីរភាព សុវត្ថិភាព និងភាពជាដៃគូ។

### ៧.៣)- កិច្ចសហប្រតិបត្តិការអន្តរជាតិ

ក្នុងបរិបទតំបន់ភាវូបនីយកម្មនិងសាកលភាវូបនីយកម្មនេះ កម្ពុជាចាត់ទុកកិច្ចសហប្រតិបត្តិការអន្តរជាតិ គឺជាយន្តការសំខាន់មួយ ដើម្បីអភិវឌ្ឍវិស័យ **ឌ-ប.គ.ព.**។ កម្ពុជាត្រូវលើកកម្ពស់តួនាទីបុរេសកម្មរបស់ខ្លួន ដើម្បីធានាឧត្តមភាពប្រកួតប្រជែងនិងការធ្វើសមាហរណកម្មសេដ្ឋកិច្ចអាស៊ាននិងចូលរួមប្រែក្លាយអាស៊ានទៅជាមជ្ឈមណ្ឌល **ប.គ.ព.** តំបន់និងមជ្ឈមណ្ឌលផ្គត់ផ្គង់ជំនាញវិជ្ជាជីវៈ **ឌ-ប.គ.ព.** ដល់ទីផ្សារការងារតំបន់។ លើសពីនេះ កម្ពុជានឹងអនុវត្តតួនាទីស្មើមុខស្មើសិទ្ធិរបស់ខ្លួន ចូលរួមសហការជំរុញកិច្ចសហប្រតិបត្តិការទ្វេភាគីនិងក្នុងក្របខ័ណ្ឌអនុតំបន់ តំបន់ និងពិភពលោក សំដៅធានាបានផលប្រយោជន៍ទៅវិញទៅមក សុខដុមនីយកម្មនៃការអភិវឌ្ឍវិស័យ **ឌ-ប.គ.ព.** និងការពារ ទប់ស្កាត់ និងឆ្លើយតបទៅនឹងរាល់ការវាយប្រហារតាមប្រព័ន្ធ **ឌ-ប.គ.ព.**។

### ៧.៤)-ការគាំទ្រថវិកា

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ជាស្ថាប័នទទួលខុសត្រូវលើថវិកាចំណាយ ស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។ ថវិកាសម្រាប់ការអនុវត្តគោលនយោបាយនេះ មានប្រភពមកពីរាជរដ្ឋាភិបាល វិស័យឯកជន ដៃគូអភិវឌ្ឍន៍

ដៃគូសន្ទនា មូលនិធិកាតព្វកិច្ចសេវាសាកល មូលនិធិការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍ ជំនួយឥត សំណង និងមកពីកិច្ចសហប្រតិបត្តិការផ្សេងៗទៀត។

### ៧.៥)-ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

ដើម្បីធានាវឌ្ឍនភាពជាប្រចាំ ប្រសិទ្ធភាព និងសង្គតិភាពនៃការអនុវត្តគោលនយោបាយ រាជរដ្ឋាភិបាលកម្ពុជា ប្រគល់ភារកិច្ចជូនក្រសួងប្រៃសណីយនិងទូរគមនាគមន៍ ជាក្រសួងមានសមត្ថកិច្ចក្នុងការតាមដាន ការត្រួតពិនិត្យ និង ការវាយតម្លៃលើការអនុវត្តគោលនយោបាយនេះ ដែលរួមមាន៖

- ការប្រៀបធៀបលទ្ធផលទៅនឹងសូចនាករដែលបានកំណត់នៅក្នុងគោលដៅនៃគោលនយោបាយ។
- ការវាយតម្លៃលើការអនុវត្តផែនការសកម្មភាពដែលបានចែងក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្រ។
- ការធ្វើរបាយការណ៍ស្តីពីវឌ្ឍនភាពនិងបញ្ហាប្រឈមនានាក្នុងការអនុវត្តគោលនយោបាយនេះរៀងរាល់ ប្រាំមួយខែម្តងជូនគណៈរដ្ឋមន្ត្រី ដើម្បីចាត់វិធានការបន្ទាន់ចាំបាច់ក្នុងការដោះស្រាយបញ្ហាប្រឈមចំពោះ មុខនិងបន្តអនុវត្តគោលនយោបាយនេះឱ្យបានជោគជ័យ។
- ការត្រួតពិនិត្យវាយតម្លៃអំពីវឌ្ឍនភាពនិងពិនិត្យគោលនយោបាយនេះឡើងវិញនៅឆ្នាំ២០១៨ ដើម្បីលើក ជាអនុសាសន៍ឱ្យមានការកែប្រែគោលនយោបាយទាន់សភាពការណ៍ស្របតាមការវិវត្តនៃបច្ចេកវិទ្យា និង និន្នាការតំបន់និងពិភពលោក។

## ៨.)- ការគ្រប់គ្រងហានិភ័យ

### ៨.១)-ហានិភ័យពាក់ព័ន្ធនឹងការសម្របសម្រួលស្ថាប័ន

ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យ **ទ-ប.គ.ព.** ឱ្យបានជោគជ័យ ទាមទារនូវឆន្ទៈនយោបាយច្បាស់ លាស់ និងរឹងមាំ និងការចូលរួមពីគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ។ ភាពខ្វះខាតនូវកត្តាណាមួយ នឹងបង្កជាបញ្ហារាំងស្ទះ ដល់ដំណើរការអនុវត្តគោលនយោបាយ ក៏ដូចជាដំណើរការអភិវឌ្ឍវិស័យ **ទ-ប.គ.ព.** និងវិស័យពាក់ព័ន្ធផ្សេងទៀត។ ដើម្បីកាត់បន្ថយហានិភ័យនេះ រាជរដ្ឋាភិបាល ប្តេជ្ញាចិត្តខ្ពស់ក្នុងការជំរុញអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និង វិធានការទាំងឡាយ ដែលត្រូវបានដាក់ចេញដើម្បីសម្រេចគោលដៅនៃការអភិវឌ្ឍវិស័យ **ទ-ប.គ.ព.**។

### ៨.២)-ហានិភ័យពាក់ព័ន្ធនឹងការវិវត្តយ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យា

បច្ចេកវិទ្យាដែលត្រូវបានប្រើប្រាស់ក្នុងវិស័យ **ទ-ប.គ.ព.** មានការវិវត្តយ៉ាងឆាប់រហ័ស។ ដូចនេះ គ្រឿងសម្ភារៈ- បរិក្ខារ **ទ-ប.គ.ព.** មួយចំនួនធំ ងាយនឹងមិនឆ្លើយតបទៅនឹងសេចក្តីត្រូវការក្នុងរយៈពេលវែង។ កត្តានេះទាមទារឱ្យ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ត្រូវរៀបចំផែនការលម្អិតយ៉ាងគត់មត់សម្រាប់រយៈពេលខ្លីនិងមធ្យម និងត្រូវ ប្រមើលមើលអំពីនិន្នាការនៃការវិវត្តនៃបច្ចេកវិទ្យា។

## ៩.)- សេចក្តីសន្និដ្ឋាន

ការអភិវឌ្ឍវិស័យ **ឧ-ប.គ.ព.** នៅកម្ពុជា កំពុងស្ថិតនៅក្នុងដំណាក់កាលប្រែប្រួលសំខាន់មួយ ជាពិសេសក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ ដែលវិស័យនេះបានចូលរួមចំណែកនិងដើរតួនាទីយ៉ាងសំខាន់នៅក្នុងជីវិតរបស់នៅរបស់ប្រជាជនកម្ពុជាទាំងនៅក្នុងទីក្រុងនិងជនបទ។ ប្រការនេះទាមទារការគិតគូអំពីអភិក្រមថ្មីពាក់ព័ន្ធនឹងការពង្រីកកាលានុវត្តអភិវឌ្ឍន៍និងការវិនិយោគក្នុងវិស័យគាំទ្រថ្មី ពិសេសតាមរយៈការកែលម្អនិងពង្រីកហេដ្ឋារចនាសម្ព័ន្ធនិងបណ្តាញឆ្អឹងខ្នងនៅទូទាំងប្រទេស ការពង្រឹងនិងការជំរុញការប្រើប្រាស់សេវា **ប.គ.ព.** ប្រកបដោយសុវត្ថិភាព សន្តិសុខ និងភាពជឿទុកចិត្ត និងការលើកកម្ពស់ចំណេះដឹងផ្នែកជំនាញ ការកសាងសមត្ថភាពនិងការស្រាវជ្រាវនិងអភិវឌ្ឍ ព្រមទាំងការពង្រឹងយន្តការស្ថាប័នប្រកបដោយសមត្ថភាពនិងមានប្រសិទ្ធភាព។

ក្នុងន័យនេះ រាជរដ្ឋាភិបាលសម្រេចដាក់ចេញនូវគោលនយោបាយអភិវឌ្ឍន៍វិស័យ **ឧ-ប.គ.ព.** សំដៅផ្តល់នូវក្របខ័ណ្ឌគោលនយោបាយនិងយន្តការដាក់លាក់សម្រាប់ជំរុញការអភិវឌ្ឍសង្គមនិងសេដ្ឋកិច្ចកម្ពុជា និងបង្កើតការងារដោយផ្តោតលើការលើកទឹកចិត្តការស្រាវជ្រាវនិងអភិវឌ្ឍ នវានុវត្តន៍ ការជំរុញនិងលើកទឹកចិត្តក្រុមហ៊ុនវ័យក្មេង និងការអភិវឌ្ឍសហគ្រាសធុនតូចនិងមធ្យម។ តាមរយៈគោលនយោបាយនេះ កម្ពុជានឹងសម្រេចបាននូវការផ្លាស់ប្តូររចនាសម្ព័ន្ធសង្គមនិងសេដ្ឋកិច្ចមួយជ្រាលជ្រៅ ដើម្បីឈានទៅសង្គមដែលមានការតភ្ជាប់គ្រប់ទីកន្លែងនិងត្រៀមខ្លួនរួចជាស្រេចក្នុងការប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ជាពិសេសឈានទៅសង្គមពឹងផ្អែកលើសេដ្ឋកិច្ចពុទ្ធិនិងសេដ្ឋកិច្ចឌីជីថល។

# ឧបសម្ព័ន្ធ
## ឧបសម្ព័ន្ធទី១ វាក្យស័ព្ទ

| ពាក្យបច្ចេកទេស | ការពន្យល់ |
|---|---|
| បច្ចេកវិទ្យាគមនាគមន៍ និង ព័ត៌មាន( **ប.គ.ព.** ) Information and Communication Technology (ICT) | បច្ចេកវិទ្យាទាំងឡាយណាដែលគ្រប់គ្រងនិងដំណើរការព័ត៌មាន។ បច្ចេកវិទ្យាទាំងនោះរួមមាន វិទ្យុ ទូរទស្សន៍ ទូរស័ព្ទ ឧបករណ៍បណ្តាញ ប្រព័ន្ធផ្កាយរណប សូហ្វវែរ ឬសូហ្វវែរកម្មវិធី ជាច្រើនទៀត។ល។ |
| សេដ្ឋកិច្ចឌីជីថល Digital Economy | សេដ្ឋកិច្ចដែលពឹងផ្អែកលើបច្ចេកវិទ្យាឌីជីថល ដូចជាអ៊ិនធឺណិតជាដើម។ល។ |
| ទូរគមនាគមន៍ Telecommunications | វិទ្យាសាស្ត្រនិងបច្ចេកវិទ្យាក្នុងការបញ្ជូន និងទទួលសំឡេង ទិន្នន័យ ស៊ីញ៉ាល់ រូបភាព ឬ ប្រភេទព័ត៌មានដទៃទៀត តាមរយៈការប្រើប្រាស់ថាមពលអេឡិចត្រូម៉ាញ៉េទិកក្រោមទម្រង់ អគ្គីសនី វិទ្យុ ពន្លឺ ឬទម្រង់ដទៃទៀត។ |
| អ៊ិនធឺណិតល្បឿនលឿន Broadband Internet | ប្រភេទអ៊ិនធឺណិត ដែលអាចបញ្ជូននិងទទួលទិន្នន័យគ្រប់ប្រភេទដូចជារូបភាព សំលេង អត្ថបទ វីដេអូ ។ល។ បានក្នុងពេលតែមួយ។ អ៊ិនធឺណិតល្បឿនលឿននេះត្រូវមានល្បឿននៃ ការបញ្ជូន ឬទទួលទិន្នន័យធំជាង ឬស្មើ 1 Mbps។ |
| អក្ខរកម្ម **ប.គ.ព.** ICT Literacy | លទ្ធភាពដែលអាចប្រើប្រាស់ **ប.គ.ព.** ដើម្បីទំនាក់ទំនង ស្វែងរក វិភាគ បង្កើត និង គ្រប់គ្រងព័ត៌មានស្របតាមផ្លូវច្បាប់និងក្រមសីលធម៌នានា។ |
| សូហ្វវែរកម្មវិធី Application Software | ជាកម្មវិធីកុំព្យូទ័រទាំងឡាយណា ដែលអាចអោយអ្នកប្រើប្រាស់ចុងក្រោយធ្វើកិច្ចការជាក់លាក់ណាមួយបាននៅលើកុំព្យូទ័រ។ |
| ពាណិជ្ជកម្មអេឡិកត្រូនិក e-Commerce | ការធ្វើពាណិជ្ជកម្មទំនិញឬសេវាតាមប្រព័ន្ធ **ប.គ.ព.** ដូចជាតាមបណ្តាញអ៊ិនធឺណិត ជាដើម។ |
| រដ្ឋាភិបាលអេឡិកត្រូនិក e-Government | ការប្រើប្រាស់ប្រព័ន្ធ **ប.គ.ព.** ដោយស្ថាប័នរដ្ឋាភិបាលដើម្បីធ្វើទំនាក់ទំនងឬផ្តល់សេវាកម្ម ដល់ប្រជាពលរដ្ឋ វិស័យឯកជន និងស្ថាប័នរដ្ឋាភិបាលផ្សេងទៀត ។ |
| ទេសចរណ៍អេឡិកត្រូនិក e-Tourism | ការប្រើប្រាស់ប្រព័ន្ធ **ប.គ.ព.** សម្រាប់ផ្តល់សេវាកម្មនានាក្នុងវិស័យទេសចរណ៍និង បដិសណ្ឋារកិច្ច។ |
| ការអប់រំតាមប្រព័ន្ធអេឡិកត្រូនិក | ការប្រើប្រាស់ប្រព័ន្ធ **ប.គ.ព.** សម្រាប់ការសិក្សាអប់រំ។ |

| | |
|---|---|
| e-Education | |
| ឧស្សាហកម្ម **ប.ទ.ព.**<br>ICT Industry | ឧស្សាហកម្មផលិតឧបករណ៍ គ្រឿងបង្គុំសម្ភារៈ **ប.ទ.ព.** និងសូហ្វវែរ និងផ្តល់សេវា **ប.ទ.ព.** ។ |
| សន្តិសុខ **ប.ទ.ព.**<br>ICT Security | ផលិតផល សេវាកម្ម ឬវិធានការទាំងឡាយណាដែលធ្វើឡើងសម្រាប់ការពារសុចរិតភាព រក្សាការសម្ងាត់និងភាពអាចប្រើប្រាស់បាននៃប្រព័ន្ធ និងទិន្នន័យ **ប.ទ.ព.**។ |
| មជ្ឈមណ្ឌលកោសល្យវិច័យឌីជីថល<br>Digital Forensic Lab | មជ្ឈមណ្ឌលដែលធ្វើកោសល្យវិច័យលើភស្តុតាងអេឡិកត្រូនិកនានា។ |
| គម្លាតឌីជីថល<br>Digital Divide | គម្លាតនៃការប្រើប្រាស់ **ប.ទ.ព.** ដូចជាទូរស័ព្ទ ទូរទស្សន៍ កុំព្យូទ័រ និងអ៊ិនធឺណិត ទៅតាមតំបន់និងប្រជាសាស្ត្រ។ |
| ធនធានវិសាលគមន៍ហ្វ្រេកង់ស៍វិទ្យុគមនាគមន៍<br>Radio Frequency Spectrum | ធនធាននៃថាមពលអេឡិកត្រូម៉ាញ៉េទិចទាំងមូល ដែលត្រូវបានផ្សាយ និងត្រូវបាន កំណត់ជាហ្វ្រេកង់ស៍ឬជំហានរលកអាកាស។ |
| ហ្វ្រេកង់ស៍វិទ្យុ<br>Radio Frequency | សំដៅដល់អត្រាលំយោលនៃរលកអាកាសវិទ្យុក្នុងថេរវេលាកំណត់មួយ។ |
| បណ្តាញខ្សែកាប្លិ៍អុបទិកក្រោមបាតសមុទ្រ<br>Submarine Cable Network | ជាបណ្តាញខ្សែកាប្លិ៍អូសឆ្លងកាត់តាមបាតសមុទ្រ សម្រាប់ផ្តល់សេវាទូរគមនាគមន៍។ |
| មជ្ឈមណ្ឌលទិន្នន័យ<br>Data Center | មជ្ឈមណ្ឌលសម្រាប់ផ្ទុកនិងផ្តល់សេវាទិន្នន័យ **ប.ទ.ព.** ។ |
| បច្ចេកវិទ្យាពពក<br>Cloud Technology | បច្ចេកវិទ្យាសម្រាប់គ្រប់គ្រងនិងចែករំលែកធនធាន **ប.ទ.ព.** នៅក្នុងមជ្ឈមណ្ឌលទិន្នន័យ ។ |
| ប្រព័ន្ធទិន្នន័យ<br>Database System | ប្រព័ន្ធមួយដែលមានទិន្នន័យ ទម្រង់ទិន្នន័យ និងប្រព័ន្ធគ្រប់គ្រងទិន្នន័យ ។ |
| បណ្តាញហេដ្ឋារចនាសម្ព័ន្ធជាតិ<br>National Information Infrastructure | បណ្តាញហេដ្ឋារចនាសម្ព័ន្ធសម្រាប់ទ្រទ្រង់ប្រព័ន្ធរដ្ឋាភិបាលអេឡិកត្រូនិក។ |
| អាសយដ្ឋានឌីអិនអែស<br>Domain Name System( DNS ) | ប្រព័ន្ធផ្តល់ឈ្មោះសម្រាប់កុំព្យូទ័រ ឧបករណ៍ ឬសេវាកម្មដទៃទៀតដែលបានភ្ជាប់ទៅនឹងបណ្តាញអ៊ិនធឺណិត ឬបណ្តាញផ្ទៃក្នុងណាមួយ។ |
| IPv4 និង IPv6 | IPv4 ជាប្រព័ន្ធផ្តល់អាសយដ្ឋានអ៊ិនធឺណិតដើមដំបូងដែលមានទម្រង់ ៣២bits។ |

| | |
|---|---|
| | IPv6 ជាប្រព័ន្ធផ្តល់អាសយដ្ឋានអ៊ិនធឺណិតបន្ទាប់ពី IPv4 មានទម្រង់ ១២៨bits។ |
| អ៊ិនធឺណិតនៃវត្ថុ<br>Internet of Things(IoT) | ការតភ្ជាប់ស្ថានភាពនៃវត្ថុ សត្វ ឬមនុស្ស ទៅនឹងប្រព័ន្ធអ៊ិនធឺណិតតាមរយៈការប្រើប្រាស់បណ្តាញទូរគមនាគមន៍ឬបច្ចេកវិទ្យាផ្សេងៗទៀត។ |
| ហេដ្ឋារចនាសម្ព័ន្ធឆ្អឹងខ្នង<br>Backbond Infrastructure | បណ្តាញមេតភ្ជាប់ទៅនឹងបណ្តាញប្រើប្រាស់ដទៃទៀតនិងមានតួនាទីចម្បងសម្រាប់លំហូរទិន្នន័យទូរគមនាគមន៍។ |
| ប្រធានផ្នែកបច្ចេកវិទ្យាព័ត៌មាន<br>Chief Information Officer<br>(CIO) | អ្នកគ្រប់គ្រងជាន់ខ្ពស់ទទួលបន្ទុកគ្រប់គ្រងប្រព័ន្ធ **ប.ត.ព.** សម្រាប់ទ្រទ្រង់ដំណើរការការងាររបស់ស្ថាប័ន។ |
| ស្តង់ដារូបនីយកម្ម<br>Standardization | ជាដំណើរការបង្កើត ឬអនុវត្ត នូវស្តង់ដាបច្ចេកទេស ដើម្បីធ្វើឱ្យបច្ចេកវិទ្យាមានគុណភាពសុវត្ថិភាពនិងសង្គតិភាព។ |
| ក្រុមការងារឆ្លើយតបទៅនឹងបញ្ហាបន្ទាន់នៃកុំព្យូទ័រ<br>CamCERT | អង្គភាពនៅក្រោមក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ដែលមានតួនាទី ការពារ ទប់ស្កាត់ ឆ្លើយតបទៅនឹងការគំរាមកំហែងនានាដែលកើតឡើងចំពោះប្រព័ន្ធកុំព្យូទ័រទាំងឡាយ។ |
| ហត្ថលេខាឌីជីថល<br>Digital Signature | បច្ចេកទេសទាំងឡាយណាដែលត្រូវបានប្រើប្រាស់សម្រាប់បញ្ជាក់អំពីអត្តសញ្ញាណ ឬភាពត្រឹមត្រូវស្របច្បាប់នៃសារ ឬឯកសារអេឡិកត្រូនិក។ |
| ហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ<br>Critical Information Infrastructure | ហេដ្ឋារចនាសម្ព័ន្ធទាំងឡាយណាដែលអាចបង្កផលប៉ះពាល់ធ្ងន់ធ្ងរដល់សង្គម សេដ្ឋកិច្ចនិងសន្តិសុខជាតិ ប្រសិនបើហេដ្ឋារចនាសម្ព័ន្ធទាំងនោះមិនដំណើរការ ឬ ត្រូវបានបំផ្លិចបំផ្លាញដោយកត្តាណាមួយ។ |
| ហេដ្ឋារចនាសម្ព័ន្ធគន្លឹះសាធារណៈ<br>Public Key Infrastructure | ជាប្រព័ន្ធដែលចងភ្ជាប់នូវគន្លឹះសាធារណៈមួយជាមួយអត្តសញ្ញាណអ្នកប្រើប្រាស់ តាមរយៈអង្គភាពផ្តល់លិខិតបញ្ជាក់។ |
| ទីប្រជុំជន<br>Urban Area | សំដៅដល់គ្រប់ទីរួមស្រុកនិងក្រុង ក្នុងរាជធានី-ខេត្តនៃព្រះរាជាណាចក្រកម្ពុជា។ |
| ទីជនបទ<br>Rural Area | តំបន់ក្រៅពីទីរួមស្រុកនិងក្រុង នៃរាជធានី-ខេត្តត្រូវចាត់ទុកថាជាទីជនបទ។ |
| អត្រាគ្រួសារដែលប្រើប្រាស់អ៊ិនធឺណិត<br>Household with Internet access | សំដៅដល់បណ្តាញអ៊ិនធឺណិត ដែលអាចត្រូវបានប្រើប្រាស់ជាទូទៅដោយសមាជិកទាំងអស់នៅក្នុងគ្រួសារនៅគ្រប់ពេល ដោយមិនគិតពីការប្រើប្រាស់ពិតប្រាកដ។ ឧបករណ៍ដែលត្រូវបានតភ្ជាប់ អាចជា ឬ មិនមែនជាកម្មសិទ្ធិរបស់សមាជិកក្នុងគ្រួសារ ប៉ុន្តែ ត្រូវចាត់ទុកជាទ្រព្យសម្បត្តិនៅក្នុងគ្រួសារ។ |

# ឧបសម្ព័ន្ធទី២ គម្រោងអាទិភាពក្នុងវិធានការគោលនយោបាយនិងផែនការសកម្មភាព

| យុទ្ធសាស្ត្រ | ផ្នែក | គម្រោងអាទិភាព | ស្ថាប័នទទួលខុសត្រូវ |
|---|---|---|---|
| ៦.១) ការពង្រឹងមូលដ្ឋានគ្រឹះនៃការអភិវឌ្ឍវិស័យ **ទ-ប.គ.ព.** | ក.ក្របខ័ណ្ឌគោលនយោបាយនិងគតិយុត្ត | ការរៀបចំគោលនយោបាយអ៊ិនធឺណិតល្បឿនលឿន ( Broadband Policy) | -ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ |
| | | ការរៀបចំគោលនយោបាយសេវាកាតព្វកិច្ចសកល (USO Policy) | -ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ |
| | | ការរៀបចំគោលនយោបាយវិសាលគមន៍វិទ្យុគមនាគមន៍ | -ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ |
| | | ការរៀបចំអនុក្រឹត្យស្តីពីវិទ្យុគមនាគមន៍ | -ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ |
| | | ការរៀបចំច្បាប់ស្តីពីការបង្ក្រាបឧក្រិដ្ឋកម្មតាមប្រព័ន្ធ **ប.គ.ព.** | -ក្រសួងមហាផ្ទៃ<br>-ក្រសួងការពារជាតិ<br>-ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍<br>-ក្រសួងពាក់ព័ន្ធ |
| | | ការរៀបចំច្បាប់ស្តីពីពាណិជ្ជកម្មអេឡិកត្រូនិក | -ក្រសួងពាណិជ្ជកម្ម<br>-ក្រសួងពាក់ព័ន្ធ |
| | | ការរៀបចំបទដ្ឋានគតិយុត្តសម្រាប់ហត្ថលេខាឌីជីថល | -ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ |
| | | ការរៀបចំការប្រើប្រាស់ធនធានទូរគមនាគមន៍កម្រឱ្យមានប្រសិទ្ធភាព | -ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍<br>-ក្រសួងពាក់ព័ន្ធ |
| | | ការរៀបចំនិងអនុម័តលិខិតបទដ្ឋានគតិយុត្តស្តីពីការការពារសិទ្ធិកុមារ និងស្ត្រីលើការប្រើប្រាស់ប្រព័ន្ធ **ប.គ.ព.** | -ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍<br>-ក្រសួងកិច្ចការនារី<br>-ក្រសួងពាក់ព័ន្ធ |
| | | ការរៀបចំការធ្វើនិយ័តកម្មលើវិស័យ **ទ-ប.គ.ព.** | -ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ |

| | | | |
|---|---|---|---|
| | | ការបង្កើនការយកចិត្តទុកដាក់លើការគ្រប់គ្រងធនធានកម្រ | -ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ |
| | | ការរៀបចំការវិនិយោគលើការស្ថាបនាខ្សែកាប្លិ៍អុបទិកក្រោមបាតសមុទ្រនិងប្រព័ន្ធផ្កាយរណប | -ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍<br>-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>-ក្រសួងពាក់ព័ន្ធ |
| | | ការជំរុញការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធអ៊ិនធឺណិតល្បឿនលឿន | -ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍<br>-ក្រសួងពាក់ព័ន្ធ |
| | | ការលើកទឹកចិត្តការប្រើប្រាស់នូវហេដ្ឋា-រចនាសម្ព័ន្ធឆ្អឹងខ្នង និងហេដ្ឋារចនាសម្ព័ន្ធរួម | -ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍<br>-ក្រសួងពាក់ព័ន្ធ |
| | ខ.ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ<br>**ឆ-ឃ.គ.ព.** | ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគាំទ្រដើម្បីពន្លឿនឌីជីថលូបនីយកម្មនៃប្រព័ន្ធសោតទស្សន៍ | -ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍<br>-ក្រសួងពាក់ព័ន្ធ |
| | | ការរៀបចំប្លង់ហេដ្ឋារចនាសម្ព័ន្ធរូបវន្តនិងបណ្តាញរួមលើផ្នែកទូរគមនាគមន៍ | -ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍<br>-ក្រសួងពាក់ព័ន្ធ |
| | | ស្ថាបនានិងពង្រីកបណ្តាញតភ្ជាប់រវាងក្រុមហ៊ុនផ្តល់សេវាអ៊ិនធឺណិតទាំងក្នុងស្រុកនិងច្រកទ្វារអន្តរជាតិ ជាពិសេសបណ្តាញតភ្ជាប់អ៊ិនធឺណិតរវាងកម្ពុជានិងអាស៊ាន | -ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍<br>-ក្រសួងពាក់ព័ន្ធ |
| | | ការធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនា-សម្ព័ន្ធព័ត៌មានជាតិ | -ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ |
| | | ការបង្កើតមជ្ឈមណ្ឌលទិន្នន័យរួមសម្រាប់រាជរដ្ឋាភិបាល | -ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ |

| | | | |
|---|---|---|---|
| | | ការបង្កើនសមត្ថភាពលើការគ្រប់គ្រងអាសយដ្ឋានអ៊ិនធឺណិត | -ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ |
| | | ការធ្វើបច្ចុប្បន្នភាពប្លង់លេខទូរគមនាគមន៍និងក្បាលលេខទូរគមនាគមន៍ជាតិ | -ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ |
| | | ការសិក្សាពីឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុលើហេដ្ឋារចនាសម្ព័ន្ធ **ឌ-ប.គ.ព.** | -ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍<br>-ក្រសួងបរិស្ថាន |
| | | ការរៀបចំនិងបង្កើតក្របខ័ណ្ឌបច្ចេកទេសដើម្បីធានាភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុរបស់ហេដ្ឋារចនាសម្ព័ន្ធ **ឌ-ប.គ.ព.** | -ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍<br>-ក្រសួងបរិស្ថាន |
| | គ.ការកាត់បន្ថយគម្លាតឌីជីថល | ការរៀបចំយន្តការសម្រាប់អនុវត្តកម្មវិធីកាតព្វកិច្ចសេវាសកលក្នុងវិស័យ **ឌ-ប.គ.ព.** | -ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍<br>-ក្រសួងពាក់ព័ន្ធ |
| | | ការជំរុញការប្រើប្រាស់ភាសាជាតិក្នុងសូហ្វវែរកម្មវិធី មាតិកាព័ត៌មាន និងឯកសារបច្ចេកទេសនានា | -ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍<br>-ក្រសួងពាក់ព័ន្ធ |
| | | ការរៀបរៀងវចនានុក្រមបច្ចេកស័ព្ទក្នុងវិស័យ **ឌ-ប.គ.ព.** | -ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍<br>-រាជបណ្ឌិតសភាកម្ពុជា<br>-ក្រសួងពាក់ព័ន្ធ |
| | | លើកកម្ពស់ការផលិត និងការប្រើប្រាស់បច្ចេកវិទ្យាជំនួយ សម្រាប់ជនពិការ | -ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍<br>-ក្រសួងពាក់ព័ន្ធ |
| | | ការប្រើប្រាស់ **ប.គ.ព.** សម្រាប់បញ្ជ្រាបការយល់ដឹងអំពីយេនឌ័រ | -ក្រសួងកិច្ចការនារី<br>-ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍<br>-ក្រសួងពាក់ព័ន្ធ |

| | | | |
|---|---|---|---|
| | ឃ.ការលើកកម្ពស់កម្រិតអក្ខរកម្មនិងការអភិវឌ្ឍធនធានមនុស្សជំនាញ **ឌ-ប.គ.ព.** | ការរៀបចំក្របខ័ណ្ឌអក្ខរកម្ម **ប.គ.ព.** ដើម្បីលើកកម្ពស់សមត្ថភាពប្រជាជនក្នុងការប្រើប្រាស់ **ប.គ.ព.** | -ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍<br>-ក្រសួងពាក់ព័ន្ធ |
| | | ការរៀបចំផែនការមេលើកកម្ពស់កម្រិតអក្ខរកម្ម **ឌ-ប.គ.ព.** ដល់មន្ត្រីរាជការសាធារណៈ | -ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍<br>-ក្រសួងមុខងារសាធារណៈ<br>-ក្រសួងពាក់ព័ន្ធ |
| | | ការបង្កើតយន្តការពិនិត្យនិងវាយតម្លៃកម្រិតយល់ដឹងនិងជំនាញប្រើប្រាស់ **ឌ-ប.គ.ព.** របស់មន្ត្រីរាជការ | -ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍<br>-ក្រសួងមុខងារសាធារណៈ<br>-ក្រសួងពាក់ព័ន្ធ |
| | | ការរៀបចំកម្មវិធីសិក្សាផ្នែក **ឌ-ប.គ.ព.** ឱ្យមានភាពសម្បូរបែបនិងទាន់សម័យសម្រាប់គ្រឹះស្ថានឧត្តមសិក្សា វិទ្យាល័យ អនុវិទ្យាល័យនិងស្ថាប័នបណ្តុះបណ្តាលជំនាញដទៃទៀត | -ក្រសួងអប់រំ យុវជននិងកីឡា<br>-ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>-ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍<br>-ក្រសួងពាក់ព័ន្ធ |
| | | ការពង្រឹងសមត្ថភាពគ្រូបង្រៀនជំនាញខាងផ្នែក **ឌ-ប.គ.ព.** និងអន្តរជំនាញ | -ក្រសួងអប់រំ យុវជននិងកីឡា<br>-ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍<br>-ក្រសួងពាក់ព័ន្ធ |
| | | ការរៀបចំប្រព័ន្ធទិន្នន័យគ្រប់គ្រងធនធានមនុស្សជំនាញ **ឌ-ប.គ.ព.** | -ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍<br>-ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>-ក្រសួងអប់រំ យុវជននិងកីឡា<br>-ក្រសួងពាក់ព័ន្ធ |
| | | ការរៀបចំគោលនយោបាយលើកកម្ពស់ជំនាញវិជ្ជាជីវៈ គ្រូបង្គោល និងអ្នកស្រាវជ្រាវក្នុងវិស័យ **ឌ-ប.គ.ព.** | -ក្រសួងអប់រំ យុវជននិងកីឡា<br>-ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ |

| | | | |
|---|---|---|---|
| | | | -ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍<br>-ក្រសួងពាក់ព័ន្ធ |
| | | ការបង្កើតមជ្ឈមណ្ឌលប្រលងយកវិញ្ញាបនបត្រឯកទេសខាងផ្នែក **ឧ-ប.គ.ព.** តាមស្តង់ដាអន្តរជាតិ | -ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍<br>-ក្រសួងអប់រំ យុវជន និងកីឡា<br>-ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>-ក្រសួងពាក់ព័ន្ធ |
| ៦.២) ការពង្រឹងសន្តិសុខនិងការអភិវឌ្ឍឧស្សាហកម្ម **ឧ-ប.គ.ព.** | ក.ការពង្រឹងសន្តិសុខ **ឧ-ប.គ.ព.** | ការបញ្ជ្រាបការយល់ដឹងខាងផ្នែកសន្តិសុខ **ឧ-ប.គ.ព.** ដល់តួអង្គពាក់ព័ន្ធ | -ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍<br>-ក្រសួងពាក់ព័ន្ធ |
| | | ការរៀបចំនិងជំរុញការអនុវត្តសេចក្តីណែនាំនិងវិធានបច្ចេកទេសផ្សេងៗស្តីពីសន្តិសុខ **ឧ-ប.គ.ព.** ដល់តួអង្គពាក់ព័ន្ធ | -ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍<br>-ក្រសួងពាក់ព័ន្ធ |
| | | ការរៀបចំក្របខ័ណ្ឌបច្ចេកទេសថ្នាក់ជាតិស្តីពីសន្តិសុខ **ឧ-ប.គ.ព.** | -ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍<br>-ក្រសួងពាក់ព័ន្ធ |
| | | ការពង្រឹងសមត្ថភាពcamCERT | -ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ |
| | | ការបង្កើតយន្តការភាពជាដៃគូរវាងស្ថាប័នរដ្ឋនិងឯកជនក្នុងការឆ្លើយតបចំពោះការគំរាមកំហែងផ្នែកសន្តិសុខ **ឧ-ប.គ.ព.** | -ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍<br>-ក្រសួងពាក់ព័ន្ធ |
| | | ការរៀបចំបទដ្ឋានបច្ចេកទេសសម្រាប់ការងារកោសល្យវិច័យឌីជីថល | -ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍<br>-ក្រសួងមហាផ្ទៃ<br>-ក្រសួងការពារជាតិ<br>-ក្រសួងពាក់ព័ន្ធ |

| | | | |
|---|---|---|---|
| | | ការបង្កើតមជ្ឈមណ្ឌលកោសល្យវិច័យឌីជីថល | -ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍<br>-ក្រសួងមហាផ្ទៃ<br>-ក្រសួងការពារជាតិ<br>-ក្រសួងពាក់ព័ន្ធ |
| | | ការបង្កើតមជ្ឈមណ្ឌលជាតិគ្រប់គ្រងហេដ្ឋារចនាគន្លឹះសាធារណៈ | -ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍<br>-ធនាគារជាតិ<br>-ក្រសួងពាណិជ្ជកម្ម<br>-ក្រសួងមហាផ្ទៃ<br>-ក្រសួងពាក់ព័ន្ធ |
| | | ការកំណត់អត្តសញ្ញាណកម្មនៃហេដ្ឋា-រចនាសម្ព័ន្ធព័ត៌មានសំខាន់ៗនិងការបង្កើតយន្តការការពារ | -ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍<br>-ក្រសួងមហាផ្ទៃ<br>-ក្រសួងការពារជាតិ<br>-ក្រសួងពាក់ព័ន្ធ |
| | ខ.ការអភិវឌ្ឍឧស្សាហកម្ម **ឌ-ប.គ.ព** | ការរៀបចំគោលនយោបាយលើកទឹកចិត្តក្នុងការបង្កើតក្រុមហ៊ុន **ប.គ.ព.** ខ្នាតតូចនិងមធ្យម និងការផ្តល់អាជ្ញាប័ណ្ណ | -ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍<br>-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| | | ការរៀបចំផែនការយុទ្ធសាស្ត្រសម្រាប់អភិវឌ្ឍន៍ឧស្សាហកម្ម **ប.គ.ព.** | -ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ |
| | | ការរៀបចំប្រព័ន្ធស្ថិតិនិងទិន្នន័យលើវិស័យ **ឌ-ប.គ.ព.** | -ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ |
| | | ការបង្កើតស្តង់ដាជាតិសម្រាប់វិស័យ **ឌ-ប.គ.ព.** | -ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍<br>-ក្រសួងពាក់ព័ន្ធ |
| | | ការរៀបចំចំណាត់ថ្នាក់ប្រតិបត្តិករទូរគមនាគមន៍ | -ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ |
| | | ការបង្កើតសួនឧស្សាហកម្ម **ប.គ.ព.** | -ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ |

| | | | |
|---|---|---|---|
| | | | -ក្រសួងពាក់ព័ន្ធ |
| | | ការរៀបចំផែនការមេសម្រាប់ការស្រាវជ្រាវនិងអភិវឌ្ឍន៍ **ប.គ.ព.** | -ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ |
| | | ការបង្កើតមូលនិធិសម្រាប់ការស្រាវជ្រាវ និងអភិវឌ្ឍ និងនវានុវត្តន៍ក្នុងវិស័យ **ឧ-ប.គ.ព.** | -ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ |
| | | ការបង្កើតយន្តការសហប្រតិបត្តិការរវាងស្ថាប័នពាក់ព័ន្ធដើម្បីចែករំលែកចំណេះដឹង ការផ្ទេរបច្ចេកវិទ្យា បទពិសោធន៍ ឧត្តមានុវត្ត និងការកសាងសមត្ថភាព | -ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ -ក្រសួងពាក់ព័ន្ធ |
| | | ការរៀបចំការប្រកួតប្រជែងលើឧស្សាហកម្មបច្ចេកវិទ្យាឈានមុខនៅកម្ពុជា | -ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ |
| | | ការរៀបចំព្រឹត្តិការណ៍បង្ហាញអំពីការវិវត្តនៃបច្ចេកវិទ្យាចុងក្រោយ | -ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ -ក្រសួងពាក់ព័ន្ធ |
| ៦.៣) ជំរុញការប្រើប្រាស់ **ប.គ.ព.** | | ការបង្កើតក្របខ័ណ្ឌបច្ចេកទេស និងយន្តការរដ្ឋាភិបាលអេឡិចត្រូនិករួមមួយ | -ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ -ក្រសួងពាក់ព័ន្ធ |
| | | ការសិក្សាស្រាវជ្រាវដើម្បីកំណត់អាទិភាពសូហ្វវែរកម្មវិធីក្នុងក្រសួងស្ថាប័នសាធារណៈ | -ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ |
| | | ការរៀបចំផែនការពង្រីកសេវារដ្ឋាភិបាលអេឡិចត្រូនិកសម្រាប់រយៈពេលខ្លី មធ្យម និងវែង | -ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ |
| | | ការបង្កើតក្រុមការងារមន្ត្រីបង្គោលទទួលបន្ទុកវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន | -ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍-ក្រសួងពាក់ព័ន្ធ |

| | | | |
|---|---|---|---|
| | ក.ការអភិវឌ្ឍ និងប្រើប្រាស់សូហ្វវែរកម្មវិធីក្នុងក្របខ័ណ្ឌរដ្ឋាភិបាលអេឡិកត្រូនិក | ការបង្កើតប្រព័ន្ធទិន្នន័យរួមថ្នាក់ជាតិ | -ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ |
| | | ការបង្កើតប្រព័ន្ធអ៊ីម៉ែលរួមសម្រាប់ស្ថាប័នរាជរដ្ឋាភិបាល | -ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ |
| | | ការបង្កើតក្របខ័ណ្ឌគេហទំព័ររួមក្នុងស្ថាប័នរដ្ឋាភិបាល | -ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ |
| | | ការបង្កើតប្រព័ន្ធចុះបញ្ជីអ្នកស្នាក់នៅ | -ក្រសួងមហាផ្ទៃ<br>-ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ |
| | | ការពង្រីកការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងមន្ត្រីរាជការ | -ក្រសួងមុខងារ-សាធារណៈ<br>-ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ |
| | | ការបង្កើតប្រព័ន្ធបញ្ជូនឯកសាររដ្ឋបាល | -ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ |
| | | ការកែលម្អនិងពង្រីកប្រព័ន្ធចុះបញ្ជីយានយន្ត | -ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ |
| | | ការកែលម្អប្រព័ន្ធបញ្ជរតែមួយជាតិ | -ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>-ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ |
| | ខ.ការជំរុញពាណិជ្ជកម្មអេឡិកត្រូនិក | ការបញ្ជ្រាបការយល់ដឹងអំពីផលប្រយោជន៍និងហានិភ័យនៃការប្រើប្រាស់ពាណិជ្ជកម្មអេឡិកត្រូនិកដល់ប្រជាជន | -ក្រសួងពាណិជ្ជកម្ម<br>-ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ |
| | | ការអភិវឌ្ឍ និងការប្រើប្រាស់ប្រតិបត្តិការទូទាត់ប្រាក់តាមប្រព័ន្ធអេឡិកត្រូនិក | -ធនាគារជាតិ<br>-ក្រសួងពាក់ព័ន្ធ |
| | | ការលើកកម្ពស់គុណភាពនិងប្រសិទ្ធភាពប្រព័ន្ធឡូជីស្ទិកនៅក្នុងពាណិជ្ជកម្មអេឡិកត្រូនិក | -ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍<br>-ក្រសួងសាធារណការ និងដឹកជញ្ជូន<br>-ក្រសួងពាក់ព័ន្ធ |

| | | | |
|---|---|---|---|
| | | ការរៀបចំយន្តការប្រមូលពន្ធនិងអាករផ្សេងៗលើពាណិជ្ជកម្មអេឡិកត្រូនិក | -ក្រសួងពាណិជ្ជកម្ម<br>-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>-ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍<br>-ក្រសួងពាក់ព័ន្ធ |
| | គ.ការប្រើប្រាស់ប្រព័ន្ធ **ឌ-ឞ.ឝ.ព.** សម្រាប់ការពារបរិស្ថាន ការសម្របនឹងការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងគ្រោះមហន្តរាយ | ការរៀបចំនិងអនុវត្តផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុក្នុងវិស័យ **ឌ-ឞ.ឝ.ព.** | -ក្រសួងបរិស្ថាន<br>-ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍<br>-ក្រសួងពាក់ព័ន្ធ |
| | | ការបង្កើតក្របខ័ណ្ឌបច្ចេកទេស **ឞ.ឝ.ព.** រួមសម្រាប់បញ្ហាបការយល់ដឹងអំពីបរិស្ថាននិងការប្រែប្រួលអាកាសធាតុ | -ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍<br>-ក្រសួងបរិស្ថាន<br>-ក្រសួងពាក់ព័ន្ធ |
| | | ការរៀបចំប្រព័ន្ធគ្រប់គ្រងទិន្នន័យរួមសម្រាប់ផ្ទុកទិន្នន័យសំខាន់ៗក្នុងការគ្រប់គ្រងគ្រោះមហន្តរាយ ការការពារបរិស្ថាននិងការប្រែប្រួលអាកាសធាតុ | -ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍<br>-ក្រសួងបរិស្ថាន<br>-ក្រសួងពាក់ព័ន្ធ |
| | | ការរៀបចំប្រព័ន្ធ **ឌ-ឞ.ឝ.ព.** សម្រាប់គ្រប់គ្រងធនធានធម្មជាតិ កាកសំណល់ និងការប្រើប្រាស់ថាមពល | -ក្រសួងបរិស្ថាន<br>-ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍<br>-ក្រសួងពាក់ព័ន្ធ |
| | | ការរៀបចំប្រព័ន្ធ **ឌ-ឞ.ឝ.ព.** សម្រាប់ត្រៀមខ្លួនឆ្លើយតបទៅនឹងគ្រោះមហន្ត-រាយ គ្រោះធម្មជាតិ និងការផ្តល់សេវាសង្គ្រោះបន្ទាន់ | -ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍<br>-គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្ត-រាយ<br>-ក្រសួងពាក់ព័ន្ធ |

## ឧបសម្ព័ន្ធទី៣ តារាងស្ថិតិ

**តារាងទី១**-ទិន្នន័យអ្នកប្រើប្រាស់សេវាទូរគមនាគមន៍

| ល.រ | ប្រភេទសេវា | | | | | | |
|---|---|---|---|---|---|---|---|
| | | ឆ្នាំ២០១០ | ឆ្នាំ២០១១ | ឆ្នាំ២០១២ | ឆ្នាំ២០១៣ | ឆ្នាំ២០១៤ | ឆ្នាំ២០១៥ |
| ១ | ទូរស័ព្ទចល័ត | ១០,៥៣៧,៦២៨ | ១៥,៦៧៨,៨២៩ | ១៩,១០៥,១១៥ | ២០,២៦៤,៥១៤ | ២០,៤៥១,៩៨២ | ២០,៨៥០,៥៤៣ |
| ២ | ទូរស័ព្ទអចល័ត | ៣៥៨,៧៥០ | ៥៥៩,៣៨១ | ៥៨៤,៤៧៥ | ៤២០,៩៤២ | ៣៦១,០៥៦ | ២៥៦,៣៨៧ |
| ៣ | អ៊ិនធឺណិត | ៣២០,១៩០ | ១,៦៨៩,៣៨៩ | ២,៧០៦,៩២២ | ៣,៨៦១,៨៤៣ | ៥,០២៥,៩៤៥ | ៦,៧៩៥,៩០៨ |

*ប្រភព:* ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ (MPTC:TRC) គិតត្រឹមឆ្នាំ២០១៥

**តារាងទី២**-ចំណាត់ថ្នាក់ទូរគមនាគមន៍-បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានក្នុងតំបន់អាស៊ានឆ្នាំ២០១៥

| | **អត្រានៃការប្រើប្រាស់សេវាទូរស័ព្ទ** | **អត្រានៃការប្រើប្រាស់សេវាអ៊ិនធឺណិត** |
|---|---|---|
| ប្រ៊ុយណេ | ១១៩,៨% | ៦៨% |
| កម្ពុជា | ១៤៧,៤៩% | ៤២,៧២% |
| ឥណ្ឌូនេស៊ី | ១១២% | ២៨% |
| ឡាវ | ១០៣% | ២១% |
| ម៉ាឡេស៊ី | ១៤៤,៨% | ៧៣,៧% |
| មីយ៉ាន់ម៉ា | ៦៧,៩៩% | ៤៦,៦៨% |
| ហ្វីលីពីន | ១១៥,១៤% | ៤៣,១៤% |
| សិង្ហបុរី | ១៤៨,៩% | ៨១% |
| ថៃ | ១៣៩,០១% | ៥៨,០៩% |
| វៀតណាម | ១៣៥% | ៣៧% |

*ប្រភព:* ការវាយតម្លៃផែនការមេបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានអាស៊ាន២០១៥

**តារាងទី៣-ការប្រៀបធៀបចំណាត់ថ្នាក់លើតម្លៃចំណាយសមស្របសម្រាប់ការប្រើប្រាស់សេវាទូរគមនាគមន៍-បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន(អ៊ិនធឺណិតនិងទូរស័ព្ទ) ក្នុងឆ្នាំ២០១៤**

| | ចំណាត់ថ្នាក់ |
|---|---|
| កម្ពុជា | ១០៥ |
| វៀតណាម | ៨ |
| ម៉ាឡេស៊ី | ៤៨ |
| ថៃ | ៤៧ |
| ឥណ្ឌូនេស៊ី | ៣៧ |
| សឹង្ហបូរី | ៤៦ |
| មីយ៉ាន់ម៉ា | ១៤៦ |
| ស្រីលង្ការ | ៣៨ |

*ប្រភព:* វេទិកាសេដ្ឋកិច្ចពិភពលោក, របាយការណ៍បច្ចេកវិទ្យាព័ត៌មានពិភពលោកឆ្នាំ២០១៤

តារាងទី៤-សូហ្វវែរកម្មវិធីដែលជាតម្រូវការអាទិភាពតាមក្រសួង-ស្ថាប័នរាជរដ្ឋាភិបាលឆ្នាំ២០១៥

| *ឈ្មោះក្រសួង-ស្ថាប័ន* | *សូហ្វវែរកម្មវិធី* |
|---|---|
| ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | ១.ប្រព័ន្ធគ្រប់គ្រងមន្ត្រីរាជការ (HRMIS)<br>២.ប្រព័ន្ធគ្រប់គ្រងឯកសារ (E-Document)<br>៣.ប្រព័ន្ធគ្រប់គ្រងឯកសារចេញចូល(E-letter)<br>៤.ប្រព័ន្ធ Billing System សម្រាប់មជ្ឈមណ្ឌលទិន្នន័យទូរគមនាគមន៍ |
| ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | ៥. ប្រព័ន្ធចុះបញ្ជីការងារសហគ្រាស<br>៦.ប្រព័ន្ធព័ត៌មានអប់រំបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ<br>៧.ប្រព័ន្ធផ្តល់ព័ត៌មានទីតាំងការងារ |
| ក្រសួងអភិវឌ្ឍន៍ជនបទ | ៨. ប្រព័ន្ធគ្រប់គ្រងបញ្ជីសារពើភ័ណ្ឌផ្លូវលំជនបទ |

| | |
|---|---|
| | ៩. ប្រព័ន្ធរដ្ឋបាលផ្ទៃក្នុង<br>១០. ប្រព័ន្ធគ្រប់គ្រងមន្ត្រីរាជការ |
| ក្រសួងទេសចរណ៍ | ១១. ប្រព័ន្ធស្ថិតិទេសចរណ៍<br>១២. ប្រព័ន្ធផ្តល់ព័ត៌មានពីសេវាកម្មទេសចរណ៍<br>១៣. ប្រព័ន្ធគ្រប់គ្រងទេសចរណ៍ |
| ក្រសួងកិច្ចការនារី | ១៤. ប្រព័ន្ធគ្រប់គ្រងរដ្ឋបាល( Administration Management System )<br>១៥. ប្រព័ន្ធគ្រប់គ្រងមន្ត្រីរាជការ( HRMS )<br>១៦.ប្រព័ន្ធគ្រប់គ្រងព័ត៌មាន( Information Management System )<br>១៧. ប្រព័ន្ធគ្រប់គ្រងការអនុវត្តគម្រោង |
| ក្រសួងការពារជាតិ | ១៨.ប្រព័ន្ធគ្រប់គ្រងរដ្ឋបាល( e-Administration ) |
| ក្រសួងសុខាភិបាល | ១៩.ប្រព័ន្ធកត់ត្រាអេឡិកត្រូនិកនិងគ្រប់គ្រងទិន្នន័យអ្នកជម្ងឺ<br>២០.ប្រព័ន្ធគ្រប់គ្រងហិរញ្ញប្បទានសុខាភិបាល<br>២១. ប្រព័ន្ធគ្រប់គ្រងការបណ្តុះបណ្តាលវិស័យសុខាភិបាល<br>២២. ប្រព័ន្ធគ្រប់គ្រងទិន្នន័យបុគ្គលិកសុខាភិបាល<br>២៣. ប្រព័ន្ធគណនេយ្យភាពសុខាភិបាលជាតិ<br>២៤. ប្រព័ន្ធគ្រប់គ្រងទាន់ហេតុការណ៍ចម្លងជម្ងឺផ្តាសាយពីសត្វទៅមនុស្ស<br>២៥. ប្រព័ន្ធគ្រប់គ្រងជម្ងឺ១០មុខ ករណីឈឺ និងស្លាប់<br>២៦. ប្រព័ន្ធសម្រាប់គ្រប់គ្រងព័ត៌មានសុខាភិបាល<br>២៧. គេហទំព័រក្រសួងសុខាភិបាល |

*ប្រភព:* ការឆ្លើយតបស្តីពីតម្រូវការប្រព័ន្ធសូហ្វវែរកម្មវិធីពីតំណាងក្រសួង-ស្ថាប័នដែលបានចូលរួមក្នុងកិច្ចប្រជុំអន្តរក្រសួង នាថ្ងៃទី១២ ខែមករា ឆ្នាំ២០១៦ នៅក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។